# ពីសក្តានុពលកាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ ទៅគំរោងយន្តការ អភិវឌ្ឍន៍ស្អាតដែលអាចសំរេចបាន ÷ ឧទាហរណ៍ពីប្រទេស កម្ពុជា ឡាវ និងវៀតណាម

# From GHGs Abatement Potential To Viable CDM Projects – The Cases Of Cambodia, Lao PDR And Vietnam


រៀបរៀងដោយ ដាង ហាញ់, អាក់សែល មីខែឡូវ៉ា, ហ្វ្រីសូ ដឺ យ៉ុង

**Dang Hanh, Axel Michaelowa, Friso de Jong**



HWWA-Report

**259**

**Hamburgisches Welt-Wirtschafts-Archiv (HWWA)**
**Hamburg Institute of International Economics**
**2006**

ISSN 0179-2253

Hamburgisches Welt-Wirtschafts-Archiv (HWWA)
Hamburg Institute of International Economics
Neuer Jungfernstieg 21 – 20347 Hamburg, Germany
Telefon: 040/428 34 355
Telefax: 040/428 34 451
e-mail: hwwa@hwwa.de
Internet: http://www.hwwa.de

The HWWA is a member of:

- Wissenschaftsgemeinschaft Gottfried Wilhelm Leibniz (WGL)
- Arbeitsgemeinschaft deutscher wirtschaftswissenschaftlicher Forschungsinstitute (ARGE)
- Association d'Instituts Européens de Conjoncture Economique (AIECE)

# ពីសក្តានុពលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទៅគំរោងយន្តការអភិវឌ្ឍន៍ស្អាតដែលអាចសំរេចបាន ៖ ឧទាហរណ៍ពីប្រទេសកម្ពុជា ឡាវ និងវៀតណាម

# From GHGs Abatement Potential To Viable CDM Projects – The Cases Of Cambodia, Lao PDR And Vietnam

រៀបរៀងដោយ ដាង ហាញ់, អាក់សែល មីខែឡូវ៉ា, ហ្វ្រីសូ ដឺ យ៉ុង

**Dang Hanh, Axel Michaelowa, Friso de Jong**

បកប្រែជាភាសាខ្មែរដោយ ទិន ពន្លក

**Translated from English into Khmer by Tin Ponlok**

ការសិក្សានេះត្រូវបានធ្វើឡើងនៅក្រោមគំរោង “*កិច្ចសហប្រតិបត្តិការផ្នែកស្ថាប័ន និងការសន្ទនាពហុជាតិ រវាងសហគមន៍អឺរ៉ុប និងអាស៊ី ស្តីពីការជំរុញការចូលរួមពិតប្រាកដរបស់កម្ពុជា ឡាវ និងវៀតណាម នៅក្នុងយន្តការអភិវឌ្ឍន៍ស្អាត*” ដែលផ្តល់មូលនិធិដោយសហគមន៍អឺរ៉ុប

ដាង ហាញ់
កម្មវិធីគោលនយោបាយអាកាសធាតុអន្តរជាតិ
វិទ្យាស្ថានសេដ្ឋកិច្ចអន្តរជាតិហាំប៊ួរ
Neuer Jungfernstieg 21, 20347 ហាំប៊ួ
អាល្លឺម៉ង់
ទូរស័ព្ទ : +4940 42834 272
ទូរសារ : +4940 42834 451
dang.hong.hanh@hwwa.de

អាក់សែល មីខែឡូវ៉ា
កម្មវិធីគោលនយោបាយអាកាសធាតុអន្តរជាតិ
វិទ្យាស្ថានសេដ្ឋកិច្ចអន្តរជាតិហាំប៊ួរ
Neuer Jungfernstieg 21, 20347 ហាំប៊ួ
អាល្លឺម៉ង់
ទូរស័ព្ទ : +49 40 42834 309
ទូរសារ : +49 40 42834 451
a-michaelowa@hwwa.de

ហ្វ្រីសូ ជី យ៉ុង
មូលនិធិបណ្តាញអនុវត្តរួមគ្នា
Meerkoetlaan 30-A, 9765 TD Paterswolde
ហុល្លង់
ទូរស័ព្ទ/ទូរសារ : +31 50 309 68 15
jiq@nina.wiwo.nl

# សេចក្តីសង្ខេប

ការសិក្សានេះវាយតម្លៃលើសក្តានុពលនៃយន្តការអភិវឌ្ឍន៍ស្អាត ឬ CDM (Clean Development Mechanism: CDM) នៅកម្ពុជា ឡាវ និងវៀតណាម ដោយពិនិត្យលើបរិមាណដាច់ខាតនៃឧស្ម័នផ្ទះកញ្ចក់ដែលអាចកាត់បន្ថយ និងទិដ្ឋភាពផ្សេងទៀតនៃបណ្តាប្រទេសទាំងនេះ ។ ក្នុងន័យនេះ សក្តានុពលនៃលំហូរ CDM ចូលទៅក្នុងប្រទេសទាំងបី នឹងត្រូវកំណត់ឡើង តាមរយៈការវាយតម្លៃប្រៀបធៀបភាពអំណោយផលដល់ CDM ផ្អែកលើមូលដ្ឋាននៃការវិភាគគ្រប់ជ្រុងជ្រោយ ដែលអាចធ្វើឱ្យលេចឡើងនូវទីតាំងធៀបរបស់កម្ពុជា ឡាវ និងវៀតណាម នៅក្នុងទីផ្សារ CDM ពិភពលោក ។

យើងនឹងសិក្សាលើកត្តាសំខាន់បី ដែលកំណត់សក្តានុពល CDM នៅកម្ពុជា ឡាវ និងវៀតណាម នៅក្នុងទីផ្សារ CDM ពិភពលោក ពោលគឺ ៖ (1) សក្តានុពលនៃទំហំការផ្គត់ផ្គង់-តួលេខរបស់ប្រទេស (2) បរិស្ថានវិនិយោគរបស់ប្រទេស និង (3) ស្ថាប័ន CDM និងបទពិសោធន៍គំរោង CDM របស់ប្រទេស ។

ការសិក្សានេះបង្ហាញពីកំរិតនៃភាពប្រកួតប្រជែងទូទៅរបស់ប្រទេសនីមួយៗ ហើយពិភាក្សាអំពីបណ្តាសកម្មភាពនានា ដែលប្រទេសនីមួយៗត្រូវអនុវត្ត ដើម្បីបង្កើននូវកាលានុវត្តភាពក្នុងការប្រែក្លាយបណ្តាជំរើសកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ផ្នែកទ្រឹស្តី ឱ្យទៅជាការវិនិយោគ CDM ជាក់ស្តែង ។

ជាឧទាហរណ៍ នៅប្រទេសវៀតណាម ការប្រឈមមុខចំបងបំផុត គឺការធ្វើឱ្យគំនិត CDM អាចយកទៅអនុវត្តបាន តាមបែបសេដ្ឋកិច្ច ។ ការសិក្សានេះបានបង្ហាញថា គេពុំទាន់ប្រាកដទេអំពីលទ្ធភាពនៃលំហូរវិនិយោគ CDM យ៉ាងគំហុកចូលក្នុងប្រទេសវៀតណាម ឬបើនិយាយពីតួលេខជាក់ស្តែងវិញ គឺថាពុំមានភាពប្រាកដនៅឡើយទេ ដែលថាគំរោង CDM ត្រឹម 10 អាចត្រូវចុះបញ្ជីនៅមុនឆ្នាំ 2012 ។

នៅប្រទេសកម្ពុជា លទ្ធភាពដែលថាគំរោង CDM ចំនួន 2-3 អាចត្រូវអនុវត្តនៅដំណាក់កាលទី 1 នៃ កាតព្វកិច្ច (2008-2012) ស្ថិតនៅក្នុងកំរិតទាប ពិតមែនតែប្រទេសនេះបានធ្វើឱ្យមានការជឿនលឿនទៅមុខច្រើន ក្នុងការបង្កើតស្ថាប័ន CDM របស់ខ្លួន បើប្រៀបធៀបជាមួយនឹងបណ្តាប្រទេសមានការអភិវឌ្ឍន៍តិចតួចផ្សេងទៀត ។ ដំណោះស្រាយមួយដែលអាចជួយឱ្យប្រើប្រាស់ឱកាសដ៏ចង្អៀតនេះ គឺការទាក់ទាញអារម្មណ៍ពីមូលនិធិកាបូនពហុភាគី ដូចជាមូលនិធិកាបូនសម្រាប់អភិវឌ្ឍសហគមន៍ (Community Development Carbon Fund: CDCF) និង មូលនិធិជីវៈកាបូន (Bio Carbon Fund: BioCF) ជាដើម ។

នៅក្នុងករណីប្រទេសឡាវវិញ ការសិក្សានេះបានបង្ហាញថា ការចូលប្រឡូកក្នុង CDM សម្រាប់ប្រទេសនេះប្រឈមនឹងការប្រកួតប្រជែងយ៉ាងខ្លាំង ដោយសារតែលក្ខខណ្ឌ CDM មិនសូវអំណោយផល និងភាពយឺតយ៉ាវរបស់រដ្ឋាភិបាល ក្នុងការរៀបចំរចនាសម្ព័ន្ធ CDM របស់ប្រទេស ។ អាស្រ័យហេតុនេះ ប្រទេសឡាវត្រូវតែខិតខំប្រឹងប្រែងថែមទៀត ក្នុងការអភិវឌ្ឍសមត្ថភាពខ្លួន ដើម្បីផ្តល់នូវក្របខ័ណ្ឌគោលគ្រប់គ្រាន់មួយ សំដៅប្រែក្លាយប្រទេសនេះឱ្យទៅជាគោលដៅ CDM មួយនៃបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច នៅក្នុងក្រសែភ្នែកអ្នកផ្តល់ជំនួយអន្តរជាតិ ។

## បញ្ជីមាតិកា


| | | |
|---|---|---|
| **១.** | **ទំហំ និងទិសដៅនៃការសិក្សា** | 7 |
| **១.១** | **វិសាលភាពនៃការសិក្សា** | 7 |
| **១.២** | **ទិសដៅនៃការសិក្សា** | 8 |
| **២.** | **សក្តានុពលនៃទីផ្សារការផ្តត់ផ្គង់ឥណទានកាបូនរបស់ប្រទេស** | 9 |
| **២.១** | **សក្តានុពល CDM របស់ប្រទេស និងកត្តាលក្ខណៈផ្នែកសេដ្ឋកិច្ច** | 9 |
| **២.២** | **វិធីសាស្ត្រពីលើ-ចុះក្រោមដើម្បីកំណត់សក្តានុពលនៃគម្រោង CDM របស់ប្រទេសនីមួយៗ** | 10 |
| | ១. ទម្រង់នៃថាមពលជាតិ | 11 |
| | ២. វិធីសាស្ត្រពីក្រោម-ទៅលើ ៖ សក្តានុពល **CDM** តាមវិស័យនានា | 17 |
| **៣.** | **បរិស្ថានវិនិយោគរបស់ប្រទេស** | 25 |
| **៣.១** | **បរិស្ថានវិនិយោគ និងភាពទាក់ទាញសម្រាប់ការវិនិយោគ CDM** | 25 |
| **៣.២** | **បរិស្ថានវិនិយោគនៅកម្ពុជា ឡាវ និងវៀតណាម** | 25 |
| **៤.** | **ស្ថាប័ន CDM និងបទពិសោធន៍គម្រោង CDM របស់ប្រទេស** | 30 |
| **៤.១** | **ស្ថាប័ន CDM របស់ប្រទេសម្ចាស់ផ្ទះ** | 30 |
| **៤.២** | **សេចក្តីសង្ខេបអំពីរចនាសម្ព័ន្ធស្ថាប័ន CDM បច្ចុប្បន្ន** | 31 |
| | ១. លក្ខខណ្ឌដំបូងសម្រាប់ចូលរួមក្នុង CDM | 31 |
| | ២. ស្ថានភាពនៃបទបញ្ញត្តិពាក់ព័ន្ធនឹង CDM | 33 |
| | ៣. ស្ថានភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងស្រុកនៅក្នុង CDM | 37 |
| **៤.៣** | **ការវាយតម្លៃស្ថាប័ន CDM របស់ជាតិ** | 39 |
| **៤.៤** | **បទពិសោធន៍ផ្នែកគម្រោងប្រែប្រួលអាកាសធាតុ** | 40 |
| **៥.** | **សេចក្តីសន្និដ្ឋាន** | 42 |
| **៥.១** | **ចំណាត់ថ្នាក់ភាពប្រកួតប្រជែងផ្នែក CDM របស់ប្រទេស** | 42 |
| **៥.២** | **សេចក្តីសន្និដ្ឋាន និងសំណើ** | 43 |
| | **ឯកសារយោង** | 46 |

# ១. វិសាលភាព និងទំរង់នៃការសិក្សា

## ១.១ វិសាលភាពនៃការសិក្សា

នៅក្នុងក្របខ័ណ្ឌនៃគំរោង "សហប្រតិបត្តិការផ្នែកស្ថាប័ន និងការសន្ទនាពហុជាតិ រវាងសហគមន៍អឺរ៉ុប និងអាស៊ី ស្តីពីការជំរុញការចូលរួមពិតប្រាកដរបស់កម្ពុជា ឡាវ និងវៀតណាម នៅក្នុងយន្តការអភិវឌ្ឍន៍ស្អាត" (ឬហៅកាត់ថា *គំរោងសន្ទនា CDM នៅក្នុងបរិបទសហគមន៍អឺរ៉ុប-អាស៊ី*) គោលបំណងដើមនៃការសិក្សានេះ គឺដើម្បីពិនិត្យមើលបរិស្ថានវិនិយោគលើគំរោង CDM នៅប្រទេសកម្ពុជា ឡាវ និងវៀតណាម ដោយផ្តោតការយកចិត្តទុកដាក់លើប្រធានបទពីរ គឺ ៖

- ការពិនិត្យឡើងវិញនូវបរិធានច្បាប់រដ្ឋាភិបាលដែលមាន ពាក់ព័ន្ធនឹងការវិនិយោគគំរោង CDM
- ការវាយតម្លៃរចនាសម្ព័ន្ធស្ថាប័នជាតិ និងក្រុមគោលដៅ សម្រាប់ការបង្កើត និងការប្រព្រឹត្តទៅនៃស្ថាប័នជាតិទទួលបន្ទុក CDM ។

បន្ទាប់ពីបានធ្វើការវិភាគលើបរិបទជាតិផ្នែកសមត្ថភាព CDM នៅក្នុងប្រទេសទាំងបី យើងបានកត់សំគាល់ឃើញថា វិធីសាស្រ្តដែលគេនិយមប្រើជាទូទៅ ក្នុងការសិក្សាកន្លងមក និងដែលកំពុងធ្វើ នៅកម្ពុជា និងវៀតណាម ដូចជាគំរោងសិក្សាយុទ្ធសាស្រ្តជាតិ (National Strategy Study: NSS) នៅវៀតណាម ឬគំរោងកសាងសមត្ថភាពជាតិសម្រាប់យន្តការអភិវឌ្ឍន៍ស្អាត (Capacity Development for the Clean Development Mechanism: CD4CDM) នៅកម្ពុជា និងវៀតណាម (ពុំមានការសិក្សាផ្នែក CDM ត្រូវបានធ្វើឡើងនៅឡាវទេ) តែងតែផ្តោតលើបណ្តាជំរើសកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់របស់ប្រទេសនីមួយៗ បន្ទាប់មកទើបគេទាញសេចក្តីសន្និដ្ឋានអំពីសក្តានុពល CDM ពីបណ្តាជំរើសទាំងនោះ ។

ជាការប្រាកដណាស់ បរិមាណឧស្ម័នផ្ទះកញ្ចក់ដែលអាចកាត់បន្ថយជាសក្តានុពល អាចជាកត្តាកំណត់នូវអនាគតនៃ CDM របស់ប្រទេសណាមួយ ។ ក៏ប៉ុន្តែ ចំនួនជំរើសកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់អាចមិនធានានូវបរិមាណលំហូរវិនិយោគ CDM ដែលសមាមាត្រ ទៅក្នុងប្រទេសម្ចាស់ផ្ទះឡើយ ។ នេះគឺដោយសារតែថា បរិមាណដាច់ខាតនៃឧស្ម័នផ្ទះកញ្ចក់ដែលអាចកាត់បន្ថយជាសក្តានុពល ពុំបានឆ្លុះបញ្ចាំងនូវបណ្តាកត្តាសំខាន់ៗផ្សេងទៀត ដែលកំណត់ការធ្វើសេចក្តីសំរេចវិនិយោគ ដូចជាកត្តានយោបាយ ហានិភ័យសេដ្ឋកិច្ច តម្លៃនៃការលះបង់ចោល ឧបសគ្គទីផ្សារ ។ល។

តាមពិត កាលានុវត្តភាពនៃ CDM (បរិមាណឧស្ម័នផ្ទះកញ្ចក់ដែលអាចកាត់បន្ថយជាសក្តានុពល) គ្រាន់តែជាកត្តាមួយ ក្នុងចំណោមកត្តាជាច្រើន ដែលគេត្រូវលើកយកមកពិចារណា ក្នុងការធ្វើសេចក្តីសំរេចវិនិយោគលើគំរោង CDM ណាមួយ ។ ដូចដែលលោក Niederberger និងលោក Saner (2005) បានគូសបញ្ជាក់ លំហូរនៃវិនិយោគ CDM ចូលទៅក្នុងប្រទេសម្ចាស់ផ្ទះណាមួយអាស្រ័យទៅនឹងកត្តាគន្លឹះបី (មើលរូបទី ១) ។

ក្នុងន័យនេះ ហើយដោយមានការលើកទឹកចិត្តពីការសាកល្បងនាំមកនូវតម្លៃបន្ថែមពីគំរោងនេះ ទើបការសិក្សារបស់យើងមិនបានវាយតម្លៃលើសក្តានុពលនៃ CDM ដោយផ្តោតការយកចិត្តទុកដាក់តែលើបរិមាណដាច់ខាតនៃឧស្ម័នផ្ទះកញ្ចក់ដែលអាចកាត់បន្ថយនោះឡើយ ។ ផ្ទុយទៅវិញ សក្តានុពលនៃលំហូរ CDM ចូលទៅក្នុងបណ្តាប្រទេសទាំងនេះនឹងត្រូវបានកំណត់ តាមរយៈការវាយតម្លៃប្រៀបធៀបភាពអំណោយផលដល់ CDM ដោយផ្អែកលើមូលដ្ឋាននៃការវិភាគគ្រប់

ជ្រុងជ្រោយសម្រាប់ប្រទេសនីមួយៗ ដែលអាចធ្វើឱ្យលេចឡើងនូវទីតាំងធៀបរបស់កម្ពុជា ឡាវ និងវៀតណាម នៅក្នុងទីផ្សារ CDM ពិភពលោក ។

តាមរយៈការបង្ហាញពីស្ថានភាពនៃសកម្មភាពរបស់ប្រទេសទាំងបីនៅលើ “ ផែនទី CDM ពិភពលោក ” ការសិក្សានេះបានលើកឡើងនូវសំណើមួយចំនួន ស្តីពីការងារ និងវិធីដែលប្រទេសនីមួយៗគួរធ្វើ ដើម្បីជំរុញឱ្យមានបរិស្ថានវិនិយោគប្រកបមួយ សម្រាប់ CDM ។




*ប្រភព ៖ Niederberger និង Saner, 2005*

*រូបទី ១. កត្តាសំខាន់ៗរបស់ប្រទេសជាម្ចាស់ផ្ទះ ដែលមានឥទ្ធិពលលើការសំរេចវិនិយោគ CDM*

យើងឱ្យនិយមន័យនៃភាពប្រកួតប្រជែងផ្នែក CDM ថាជា “រង្វាស់នៃមធ្យោបាយដែលប្រទេសមួយមាន សម្រាប់ជំរុញគំរោង CDM នៅក្នុងប្រទេស ធៀបជាមួយនឹងការប្រកួតប្រជែងពិភពលោក ” ។

## ១.២ ទំរង់នៃការសិក្សា

កត្តាសំខាន់បី ដែលកំណត់ភាពប្រកួតប្រជែងរបស់កម្ពុជា ឡាវ និងវៀតណាម នៅក្នុងទីផ្សារ CDM ពិភពលោក នឹងត្រូវលើកយកមកសិក្សានៅក្នុងជំពូកមួយដាច់តែឯង ។ ជំពូកទី ២ នឹងពិភាក្សាអំពី "សក្តានុពលនៃទំហំការផ្គត់ផ្គង់-តួលេខរបស់ប្រទេស" ។ ជំពូកទី ៣ នឹងអធិប្បាយអំពី "បរិស្ថានវិនិយោគរបស់ប្រទេស" ហើយជំពូក ៤ និយាយអំពី "ស្ថាប័ន CDM និងបទពិសោធន៍គំរោង CDM របស់ប្រទេស" ។ នៅជំពូកចុងក្រោយ នឹងមានសេចក្តីសន្និដ្ឋាន ព្រមទាំងមានអធិប្បាយអំពីភាពប្រកួតប្រជែងទូទៅរបស់ប្រទេសនីមួយៗ ។ នៅក្នុងការអធិប្បាយអំពីភាពប្រកួតប្រជែងនេះ យើងនឹងពិភាក្សាអំពីបណ្តាសកម្មភាពនានា ដែលប្រទេសនីមួយៗត្រូវអនុវត្ត ដើម្បីបង្កើននូវកាលានុវត្តភាពនៃការប្រែក្លាយបណ្តាជំរើសកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជាទ្រឹស្តី ឱ្យទៅជាការវិនិយោគផ្នែក CDM ជាក់ស្តែង ។

## ២. សក្តានុពលនៃទំហំការផ្គត់ផ្គង់_តួលេខរបស់ប្រទេស

### ២.១ សក្តានុពល CDM របស់ប្រទេស និងកត្តាលទ្ធភាពផ្នែកសេដ្ឋកិច្ច

CDM គឺជាយន្តការដែលកំណត់ដោយកម្លាំងទីផ្សារ ។ គេអាចញែកដាច់ពីគ្នារវាងកត្តាផ្គត់ផ្គង់ និងកត្តាតំរូវការនៅក្នុងការកំណត់លំហូរវិនិយោគ CDM ចូលទៅក្នុងប្រទេសណាមួយ ។ ការកំណត់ទាំងនេះក៏មានភាពខុសគ្នា តាមរយៈកត្តាខាងក្នុង (អាស្រ័យទៅលើប្រទេសម្ចាស់ផ្ទះផ្ទាល់) និងកត្តាខាងក្រៅ (អាស្រ័យទៅលើអ្នកវិនិយោគ និងទីផ្សារអន្តរជាតិ) ។ ជាទូទៅ អាស្រ័យដោយកត្តាទាំងនេះ ការវិនិយោគ CDM អាចហូរចូលទៅក្នុងប្រទេសទាំងឡាយណា ដែលអាចបង្កើតនូវការកាត់ឧស្ម័នផ្ទះកញ្ចក់ដែលត្រូវបានបញ្ជាក់ (Certified Emission Reductions: CERs) ដែលមានតម្លៃថោក ក្នុងបរិមាណច្រើនសមល្មម ។

ដោយសារតែការចំណាយខ្ពស់របស់គំរោង CDM បើធៀបទៅនឹងតម្លៃទាបនៃ CERs នៅក្នុងទីផ្សារកាបូន នោះគំរោង CDM ត្រូវតែមានទំហំធំសមល្មម ដើម្បីឱ្យអាចអនុវត្តបានតាមបែបសេដ្ឋកិច្ច ។ នេះគឺជាឧបសគ្គដ៏ធំមួយសម្រាប់បណ្តាប្រទេសតូចៗ ដែលមានសក្តានុពលគំរោង CDM តិចតួច ។ ការសិក្សាវិភាគនានាបានបង្ហាញថា យ៉ាងហោចណាស់ក៏បរិមាណអតិបរមាត្រូវស្មើនឹងប្រហែល 20.000 តោន $CO_2$ ក្នុងមួយឆ្នាំ សម្រាប់គំរោង CDM ធម្មតា បើទោះជាក្នុងករណីដែលគេអាចយកមកប្រើបាននូវវិធីសាស្ត្រលក្ខខណ្ឌគោល និងការអង្កេតតាមដាន ដែលបានអនុម័តរួចហើយក្តី (Michaelowa and Jotzo, 2005) ។ បច្ចុប្បន្ន គេនៅពុំទាន់រកបាននូវពត៌មានស្តីពីចំនួនជាសក្តានុពលនៃគំរោង CDM ខ្នាតតូចនៅឡើយទេ ។ ក៏ប៉ុន្តែ ការសិក្សាមួយរបស់ Point Carbon (2002) បានសន្និដ្ឋានថា កាលានុវត្តភាពសម្រាប់មុខជំនួញនៃគំរោង CDM ខ្នាតតូច នៅមានកំរិតទាបណាស់ ដោយសារតែការបារម្ភពីហានិភ័យនៃគំរោង ឧបសគ្គពាក់ព័ន្ធនឹងការចំណាយបន្ថែម និងបញ្ហាពាក់ព័ន្ធនឹងវិធានសំរួលរបស់គំរោងខ្នាតតូច ។ ការវាយតម្លៃថ្មីៗមួយ (Haites, 2004) បានបង្ហាញថា បណ្តាគំរោងដែលបង្កើតតិចជាង 1000.000 CERs ក្នុងមួយឆ្នាំ ប្រហែលជាពុំអាចមានប្រសិទ្ធភាពសេដ្ឋកិច្ចក្រោម CDM ទេ ។ ទំហំអតិបរមានៃគំរោងអាចខុសៗគ្នាយ៉ាងខ្លាំង ពីការសិក្សាមួយ ទៅការសិក្សាមួយទៀត ដោយសារតែការវាយតម្លៃខុសគ្នា និងការសន្មតខុសគ្នា ពាក់ព័ន្ធនឹងកត្តាទីផ្សារនានា ដូចជា តំរូវការ ការផ្គត់ផ្គង់ ថ្លៃ ក៏ដូចជាការព្យាករស្តីពីការប្រែប្រួលបរិស្ថានគោលនយោបាយអន្តរជាតិ និងនៅក្នុងតំបន់ ដែលការសិក្សានីមួយៗបានកំណត់យក ។ បច្ចុប្បន្ន មានគំរោងជាច្រើន ដែលមានបរិមាណកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រចាំឆ្នាំ នៅចន្លោះ 10-20.000 $tCO_2$ ត្រូវបានគេដាក់ជូនសម្រាប់ធ្វើសុពលភាព ដែលការណ៍នេះបង្ហាញពីឥទ្ធិពលនៃការរំពឹងទុកថាតម្លៃ CER នឹងកើនឡើង ។

ការព្យាករមកទល់បច្ចុប្បន្នបង្ហាញថា ប្រមាណ 70% នៃការវិនិយោគ CDM នឹងត្រូវចូលទៅប្រទេសចិន និងឥណ្ឌា (Michaelowa and Jotzo, 2005) ។ ដូច្នេះ បណ្តាប្រទេសកំពុងអភិវឌ្ឍ និងប្រទេសមានការអភិវឌ្ឍតិចតួចផ្សេងទៀត ត្រូវតែប្រកួតប្រជែងគ្នា ដើម្បីដណ្តើមយកបរិមាណ 30% ដែលនៅសល់ ។ គួរកត់សំគាល់ថា របាយពុំស្មើគ្នាបែបនេះ មានភាពផ្ទុយគ្នានឹងស្មារតីនៃពិធីសារក្យូតូ ។ ទោះជាយ៉ាងណាក្តី និន្នាការជាក់ស្តែងនៃទីផ្សារកាបូនពិភពលោកបង្ហាញថា CDM គ្របដណ្តប់នៅប្រទេសមួយចំនួនតូច តាមរយៈគំរោងធំៗមួយចំនួនតូច ។ មកទល់ថ្ងៃទី 11 ខែវិច្ឆិកា ឆ្នាំ 2005

ប្រទេសប្រេស៊ីល ចិន ឥណ្ឌា និងកូរ៉េខាងត្បូង រួមគ្នាមានចំណែកប្រមាណ 75% នៃបរិមាណ CER ដែលគេរំពឹងទុក រហូតដល់ឆ្នាំ 2012 ដែលនៅក្នុងនោះ 32% នៃបរិមាណនេះនឹងបានមកពីគំរោងតែប្រាំប៉ុណ្ណោះ ។

ផ្ទុយពីនិន្នាការនៃទីផ្សារ CDM ជាបឋមយើងពិនិត្យមើលបរិមាណឧស្ម័នផ្ទះកញ្ចក់អាចកាត់បន្ថយ ដែលអាចទទួលយកបានពីគំរោង CDM នៅក្នុងប្រទេសទាំងបី តាមរយៈវិធីសាស្ត្រពីលើ-ចុះក្រោម និងពីក្រោម-ឡើងលើ ។

## ២.២ វិធីសាស្ត្រពីលើ-ចុះក្រោមដើម្បីកំណត់សក្តានុពលនៃគំរោង CDM របស់ប្រទេសនីមួយៗ

ជាទូទៅ វិធីសាស្ត្រពីលើ-ចុះក្រោមសម្រាប់វាយតម្លៃសក្តានុពល CDM របស់ប្រទេសជាម្ចាស់ផ្ទះណាមួយ ត្រូវបានគេយកមកប្រើប្រាស់ នៅក្នុងការសិក្សាថ្នាក់ជាតិ ស្តីពីសក្តានុពល CDM ដូចដែលមានបង្ហាញនៅក្នុងរូបទី ២ ។




*រូបទី ២. វិធីសាស្ត្រពីលើចុះក្រោមដើម្បីកំណត់សក្តានុពលគំរោងCDM របស់ប្រទេស*

មកទល់បច្ចុប្បន្ន លើកលែងតែនៅប្រទេសឡាវ ដែលការសិក្សាអំពីសក្តានុពល CDM ទើបតែត្រូវបានចាប់ផ្តើម គេធ្វើការសិក្សាបណ្តាជំរើសកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងសក្តានុពល CDM តាមរយៈបណ្តាគំរោងកសាងសមត្ថភាពមួយចំនួន នៅប្រទេសកម្ពុជា និងវៀតណាម (សូមអានគំរោង CD4CDM និង IGES សម្រាប់ប្រទេសកម្ពុជា និងគំរោង ALGAS, CD4CDM, NSS សម្រាប់ប្រទេសវៀតណាម) ដោយប្រើវិធីសាស្ត្រពីលើចុះក្រោម ។ ទោះជាយ៉ាងណាក្តី ដូចដែលបានពិភាក្សានៅក្នុងសេចក្តីផ្តើម បរិមាណដាច់ខាតនៃឧស្ម័នផ្ទះកញ្ចក់ដែលអាចកាត់បន្ថយជាសក្តានុពល ពុំអាចឆ្លុះបញ្ចាំងឱ្យបានត្រឹមត្រូវ នូវជំហររបស់ប្រទេសមួយ នៅក្នុងទីផ្សារ CDM ពិភពលោកបានឡើយ ។ អាស្រ័យហេតុនេះ ការសិក្សានេះនឹងប្រើប្រាស់នូវវិធីប្រៀបធៀប ដែលអាចវាយតម្លៃសមត្ថភាពផ្នែក CDM របស់ប្រទេសនីមួយៗ ដែលយកមកសិក្សា ដោយប្រៀបធៀមជាមួយនឹងបណ្តាតម្លៃរបស់ប្រទេសជិតខាង ។ សន្ទស្សន៍ទាក់ទងនឹងវិស័យថាមពល របស់ប្រទេសជាតិនីមួយៗ នឹងត្រូវលើកយកមកប្រើ ។

យើងផ្តោតការយកចិត្តទុកដាក់លើបណ្តាសន្ទស្សន៍ថាមពល ពីព្រោះសក្តានុពលកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ភាគច្រើន មាននៅក្នុងវិស័យថាមពល ។ ជាការពិតដែលថា គំរូនៃផលិតកម្ម និងការប្រើប្រាស់ថាមពល មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាតិ និងជំរើសកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ។ លើសពីនេះ ការដាំព្រៃឈើ និងការស្តារព្រៃឈើ (LULUCF) តំណាងឱ្យតែភាគរយតិចតួចប៉ុណ្ណោះ នៅក្នុងបណ្តាវិធីសាស្ត្រដែលដាក់ជូនពិនិត្យ ហើយនិន្នាការនេះក៏ប្រហែលជានឹងមានការប្រែប្រួលជាដុំកំភួនដែរ នាពេលអនាគតឆាប់ៗខាងមុខនេះ ពិតមែនតែមានវិធីសាស្ត្រមួយចំនួនទៀតកំពុងត្រូវបានស្នើឡើង ដើម្បីសុំការអនុម័តពិសេសសម្រាប់ក្រុមការងារផ្នែកការដាំព្រៃឈើ និងការស្តារព្រៃឈើក្តី ។

នៅក្នុងជំពូកនេះ យើងបានជ្រើសរើសយកប្រទេសឥណ្ឌូនេស៊ី និងថៃ ជាក្រុមគោល ដើម្បីបង្ហាញពីសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសទាំងបី នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍នេះ ។ មូលហេតុនៃការជ្រើសរើសយកប្រទេសទាំងពីរនេះ គឺភាពងាយស្រួលក្នុងការរកទិន្នន័យ សកម្មភាពរបស់ប្រទេសទាំងពីរនៅក្នុង CDM និងភាពជិតស្និទ្ធ ក៏ដូចជាភាពស្រដៀងគ្នា នៃរចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ច ជាមួយនឹងប្រទេសទាំងបី ដែលលើកយកមកសិក្សា ។

## ១. ទម្រង់នៃថាមពលជាតិ

### *ក. សក្តានុពលថាមពលបឋម*

អំណោយទានធនធានធម្មជាតិរបស់ជាតិ ជាពិសេសធនធានថាមពល គឺជាកត្តាមួយ ដែលកំណត់ទស្សនវិស័យនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសមួយ ។ នៅក្នុងជំពូកនេះ យើងនឹងប្រើសក្តានុពលថាមពលបឋមដាច់ខាត ជារង្វាស់នៃអំណោយទានផ្នែកថាមពល (មើលតារាងទី ១) ដោយសារថា អថេរនេះមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងនិន្នាការផលិត និងប្រើប្រាស់ថាមពលរបស់ប្រទេស ។

*តារាងទី ១. សក្តានុពលថាមពលបថម*

| ប្រទេស | ប្រភេទថាមពល | | | | | **ចំណាត់ថ្នាក់ភាពអំណោយទានផ្នែកថាមពល** |
|---|---|---|---|---|---|---|
| | ប្រេងកាត (ពាន់លានបារ៉ែល) | ឧស្ម័នធម្មជាតិ (លានលានហ្វីតគូប) | ធ្យូងថ្ម (លានតោន) | ថាមពលវារី-អគ្គិសនី (GW) | ថាមពលឈើ (លានតោន) | |
| កម្ពុជា | -- | 9,9 | -- | 10 | 82 | **5** |
| ឡាវ | -- | 3,6 | 600 | 26,5 | 46 | **4** |
| វៀតណាម | 4 | 21,9 | អង់ត្រាស៊ីត ៖ 3.500 លីញីត ៖ 150.000 | 68,5 | 49 | **2** |
| ឥណ្ឌូនេស៊ី | 10 | 169,5 | 38.000 | 75,6 | 439 | **1** |
| ថៃ | 0,16 | 12,2 | 1.240 | N/A. | 67 | **3** |

*ប្រភពទិន្នន័យថាមពល ៖ មជ្ឈមណ្ឌលថាមពលអាស៊ាន*

តារាងទី ១ បង្ហាញថា បើធៀបជាមួយប្រទេសឥណ្ឌូនេស៊ី និងថៃ ប្រទេសវៀតណាមមានអំណោយទានពីធម្មជាតិល្អ ដោយមានធ្យូងថ្មសំបូរហូរហៀរ ហើយមានធនធានប្រេងកាត និងវារីអគ្គិសនីមធ្យម ។ ប្រទេសកម្ពុជា និងឡាវ មានមូលដ្ឋានធនធានថាមពលក្នុងស្រុកតិចតួច ទាំងបរិមាណដាច់ខាត ទាំងប្រភេទផ្សេងៗនៃធនធាន ។

ជួរឈរចុងក្រោយនៃតារាងទី ១ ចាត់ថ្នាក់ប្រទេស ដោយអនុលោមតាមអំណោយទានរបស់ប្រទេសទាំងនោះផ្នែកធនធានធម្មជាតិ ។ បើនិយាយពីសិទ្ធិទទួលយកជាគំរោង CDM វិញ យើងឃើញថា ប្រទេសណាដែលសំបូរធនធានធម្មជាតិបថមច្រើន ប្រទេសនោះក៏មានសក្តានុពលក្នុងការអភិវឌ្ឍ CDM ខ្ពស់ដែរ ។

## *ខ. ការប្រើប្រាស់ថាមពល*

ភាពអំណោយទាននៃធនធានធម្មជាតិ គឺជាកត្តាអនុគ្រោះសម្រាប់អភិវឌ្ឍមួយ ប៉ុន្តែមិនមែនសុទ្ធតែបង្ហាញពីកំរិតនៃការអភិវឌ្ឍរបស់ប្រទេសមួយឡើយ ឧទាហរណ៍ ដូចជាប្រទេសជប៉ុនជាដើម ។ អាស្រ័យហេតុនេះ យើងនឹងសិក្សាលើបណ្តាសូចនាករ ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ថាមពលជាក់ស្តែងរបស់ប្រទេសទាំងនេះ ។ ដើម្បីបង្ហាញនូវទំនាក់ទំនងរវាងសូចនាករសេដ្ឋកិច្ច និងសូចនាករប្រើប្រាស់ថាមពល យើងនឹងដាក់បញ្ចូលនូវផលិតផលក្នុងស្រុកសរុប (GDP) សម្រាប់មនុស្សម្នាក់ របស់ប្រទេសនីមួយៗ ទៅក្នុងសូចនាករថាមពល នៅក្នុងតារាងទី ២ ។

*តារាងទី ២. សូចនាករការប្រើប្រាស់ថាមពលនៅឆ្នាំ ២០០២*

| ប្រទេស | ការប្រើប្រាស់អគ្គិសនីសរុប (លានលាន Wh) | ការប្រើប្រាស់អគ្គិសនីសម្រាប់ម្នាក់ (kWh/ឆ្នាំ) | ប្រពលភាពថាមពល (kWh/$1995) | ផលិតផលក្នុងស្រុកសរុបសម្រាប់ម្នាក់ ($) |
|---|---|---|---|---|
| កម្ពុជា | 2,3 | 175,8 | 0,6 | 1.900 |
| ឡាវ | 11,7 | 2.110,1 | 4,41 | 1.700 |
| វៀតណាម | 255 | 3.165,2 | 7,68 | 2.500 |
| *ឥណ្ឌូនេស៊ី* | *1.305* | *6.008* | *5,96* | *3.200* |
| *ថៃ* | *9.015* | *14.360,5* | *4,89* | *7.400* |

*ប្រភព ៖ ស្ថិតិថាមពលផ្លូវការពីរដ្ឋាភិបាលសហរដ្ឋអាមេរិច*

សូចនាករប្រើប្រាស់ថាមពលឆ្លុះបញ្ចាំងនូវកំរិតអភិវឌ្ឍន៏សេដ្ឋកិច្ចនិងឧស្សាហកម្ម រចនាសម្ព័ន្ធសេដ្ឋកិច្ច និងលំនាំនៃការប្រើប្រាស់របស់ប្រទេសណាមួយ ។ ប្រពលភាពថាមពល (energy intensity) វាស់វែងនូវបរិមាណថាមពល ដែលត្រូវការសម្រាប់ផលិតនូវ GDP គិតជាដុល្លារ ហើយវានឹងថយចុះ នៅពេលដែលប្រសិទ្ធភាពថាមពលកើនឡើង ។ ដូច្នេះប្រពលភាពថាមពលអាចត្រូវយកមកប្រើប្រាស់ជាសូចនាករមួយ (ពិតមែនតែវាមិនសុក្រឹតក្តី) ដែលបង្ហាញពីសក្តានុពលក្នុងការលើកកំពស់ប្រសិទ្ធភាពថាមពលរបស់ប្រទេសណាមួយ (Fankhauser, 2003) ។

រូបទី ៣. បង្ហាញថា កម្ពុជា ឡាវ និងវៀតណាម គឺជាប្រទេសបីដែលមានសេដ្ឋកិច្ចពឹងលើកសិកម្មជាមូលដ្ឋាន ដែលក្នុងនោះ វិស័យកសិកម្មតំណាងឱ្យលើសពី 20% នៃ GDP សរុប នៅឆ្នាំ 2002 ។




*ប្រភព ៖ សៀវភៅស្ថិតិធនាគារពិភពលោក*

*រូបទី ៣. សមាសភាពនៃ GDP តាមវិស័យ*

ប្រសិនបើដាក់បញ្ចូលគ្នានូវតារាងទី ២ និងរូបទី ៣ នោះយើងឃើញថា GDP សម្រាប់មនុស្សម្នាក់ និងភាគចំណែកនៃ GDP តាមឧស្សាហកម្ម និងសេវាកម្ម សមាមាត្រទៅនឹងកំរិតនៃការប្រើប្រាស់ថាមពល ។ នៅក្នុងករណីប្រទេសកម្ពុជា និងឡាវ យើងឃើញថា ចំណែកថ្នាក់ GDP សម្រាប់មនុស្សម្នាក់ទាបជាងគេ ក្នុងចំណោមប្រទេសទាំងប្រាំ និងតួនាទីចំបងនៃវិស័យកសិកម្មនៅក្នុងសេដ្ឋកិច្ច ហាក់ដូចជាត្រូវគ្នាជាមួយនឹងកំរិតប្រើប្រាស់ថាមពលដ៏ទាប ។ ពិតមែនតែប្រពលភាពថាមពលរបស់ប្រទេសឡាវមានកំរិតខ្ពស់សឹងតែស្មើនឹងប្រទេសថៃក្តី ក៏នេះប្រហែលជាបណ្តាលមកពីប្រសិទ្ធភាពទាបនៃការប្រើប្រាស់ប្រភពថាមពល តែមិនមែនជាការឆ្លុះបញ្ចាំងនូវស្ថានភាពឧស្សាហូបនីយកម្មរបស់ប្រទេសទេ ។ ការប្រើប្រាស់ថាមពលក្នុងមនុស្សម្នាក់នៅវៀតណាមមានកំរិតខ្ពស់ជាងនៅកម្ពុជា និងឡាវ ក៏ប៉ុន្តែកំរិតនេះនៅតែទាបជាងកំរិតប្រើប្រាស់នៅប្រទេសឥណ្ឌូនេស៊ី និងថៃ ។ ការណ៍នេះមានភាពត្រូវគ្នាជាមួយនឹងអត្រា GDP សម្រាប់មនុស្សម្នាក់របស់វៀតណាមនិង GDP សម្រាប់មនុស្សម្នាក់របស់ឥណ្ឌូនេស៊ី និងថៃ ។

ការវិភាគ GDP សម្រាប់មនុស្សម្នាក់ និងការប្រើប្រាស់ថាមពលសម្រាប់មនុស្សម្នាក់ នៅក្នុងប្រទេសជាសមាជិកនៃអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (Organisation of Economic Cooperation and Development: OECD) និងប្រទេសមិនមែនជាសមាជិក OECD បានបង្ហាញឱ្យឃើញពីទំនាក់ទំនងរវាងកំរិតនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសក្តានុពលសម្រាប់លើកកំពស់ប្រសិទ្ធភាពថាមពល (រូបទី ៤) ។

ទំនាក់ទំនងនេះពុំមែនជាទំនាក់ទំនងលីនេអ៊ែរ ធៀបជាមួយនឹងស្ថានភាពអភិវឌ្ឍន៍សេដ្ឋកិច្ច គិតតាម GDP សម្រាប់មនុស្សម្នាក់ទេ ។ Sakamoto (2003) បានកំណត់ភាពខុសគ្នានៃទំនាក់ទំនងនេះ ជាបីកំរិតនៃ GDP សម្រាប់មនុស្សម្នាក់ ដូចខាងក្រោម ៖

ដំណាក់កាលទី ១ ៖ GDP សម្រាប់មនុស្សម្នាក់ទាប → ការលើកកំពស់ប្រសិទ្ធភាពថាមពល

ដំណាក់កាលទី ២ ៖ GDP សម្រាប់មនុស្សម្នាក់មធ្យម → ការធ្លាក់ចុះប្រសិទ្ធភាពថាមពល

ដំណាក់កាលទី ៣ ៖ GDP សម្រាប់មនុស្សម្នាក់ខ្ពស់ → ការលើកកំពស់ប្រសិទ្ធភាពថាមពល ។

នៅក្នុងទស្សនៈនេះ ដំណាក់កាលដំបូងនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសទាំងបី នាំមកនូវកាលានុវត្តភាពសម្រាប់លើកកំពស់ប្រសិទ្ធភាពថាមពល នៅក្នុងប្រទេស ។ ដូច្នេះ ជាទ្រឹស្តីប្រទេសទាំងបីមានកាលានុវត្តភាពសម្រាប់បណ្តាគំរោង CDM ក្នុងផ្នែកលើកកំពស់ប្រសិទ្ធភាពថាមពល ។




*ប្រភព ៖ Sakamoto (2003)*

*រូបទី ៤. GDP ក្នុងមនុស្សម្នាក់ និងការប្រើប្រាស់ថាមពល (សម្រាប់ GDP ក្នុងមនុស្សម្នាក់)*

*(ប្រទេសអភិវឌ្ឍន៍ ៖ 1960 - 2000, ប្រទេសកំពុងអភិវឌ្ឍន៍ ៖ 1971 - 2000)*

### *គ. ការបញ្ចេញឧស្ម័ន $CO_2$ ពីវិស័យថាមពល*

ដោយសារតែមានភាពមិនច្បាស់លាស់ខ្ពស់ ទាក់ទងនឹងការវិវត្តនាពេលអនាគតនៃ CDM នោះ ជាទូទៅអ្នកវិនិយោគតែងវាយតម្លៃយ៉ាងគ្រប់ជ្រុងជ្រោយនូវភាពអាចដំណើរការបានជាសក្តានុពលនៃគំរោង ជាជាងដោយគ្រាន់តែផ្តោតទៅលើតែករណីណាមួយ ។ នៅក្នុងចំណោមបណ្តាកត្តាបរិមាណ និងកត្តាគុណភាពដ៏សំបូរបែប សក្តានុពលនៃការកាត់បន្ថយឧស្ម័ន គឺជាកត្តាសំខាន់មួយនៃភាពអាចដំណើរការបានជាសក្តានុពល ដែលអ្នកវិនិយោគលើកយកមកពិចារណា ក្នុងការធ្វើសេចក្តីសម្រេចវិនិយោគលើ CDM ។ នៅក្នុងការសិក្សានេះ យើងផ្តោតការយកចិត្តទុកដាក់តែលើសក្តានុពលនៃការកាត់បន្ថយឧស្ម័ន $CO_2$ នៅក្នុងវិស័យថាមពល ដោយសារតែមានការលំបាកក្នុងការរកទិន្នន័យដែលអាចជឿជាក់ និងប្រៀបធៀបគ្នាបាន សម្រាប់ឧស្ម័នផ្ទះកញ្ចក់ដទៃទៀត នៅក្នុងប្រទេសទាំងបី ។

*តារាងទី ៣. ការបញ្ចេញឧស្ម័ន $CO_2$ ពីវិស័យថាមពល*

| ប្រទេស | សូចនាករបញ្ចេញឧស្ម័ន $CO_2$ ពីវិស័យថាមពល នៅឆ្នាំ 2002 | | |
|---|---|---|---|
| | ការបញ្ចេញឧស្ម័ន $CO_2$ ពីការប្រើប្រាស់ និងការដុតឧស្ម័នដែលភាយចេញឥន្ធនៈផូស៊ីល (លានតោន) | ការបញ្ចេញឧស្ម័ន $CO_2$ ក្នុងមនុស្សម្នាក់ (តោន) | ប្រពលភាព $CO_2$ : តោន/ពាន់ដុល្លារ 1995 |
| កម្ពុជា | 0,57 | 0,04 | 0,14 |
| ឡាវ | 0,39 | 0,07 | 0,15 |
| វៀតណាម | 51,9 | 0,7 | 0,39 |
| *ឥណ្ឌូនេស៊ី* | *299,80* | *1,38* | *1,37* |
| *ថៃ* | *188,62* | *3,01* | *1,02* |

*ប្រភព ៖ ស្ថិតិថាមពលផ្លូវការពីរដ្ឋាភិបាលសហរដ្ឋអាមេរិច*

សមត្ថភាពនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅក្នុងប្រទេសនីមួយៗអាចត្រូវកំណត់ ដោយផ្អែកលើសូចនាករទាំងបីដែលបានលើកឡើងនៅក្នុងតារាងទី ៣ ។ សូចនាករទាំងនេះគឺ ៖

១. សក្តានុពលក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ៖ អាចគណនាបាន តាមរយៈការវាស់វែងនូវភាគរយនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ប្រទេស ធៀបទៅនឹងការបញ្ចេញឧស្ម័នរបស់ពិភពលោក (តម្លៃដាច់ខាតនៃការបញ្ចេញឧស្ម័នកាបូនិចសរុប ពីការប្រើប្រាស់ និងពីការដុតឧស្ម័នដែលភាយចេញពីឥន្ធនៈផូស៊ីល)

ដើម្បីឱ្យងាយយល់ យើងធ្វើការប្រៀបធៀបសូចនាករពីរទៀតនៅក្នុងតារាងទី ៣ ជាមួយនឹងសូចនាកររបស់សហរដ្ឋអាមេរិច ដែលគេប្រើជាឯកតាមានមាត្រដ្ឋាន (100%) ដើម្បីទាញយកសូចនាករពីរខាងក្រោម ៖

២. សក្តានុពលក្នុងការលើកកំពស់ប្រសិទ្ធភាពថាមពល (តម្លៃដាច់ខាតអាចគណនាដោយប្រើការបញ្ចេញ $CO_2$ សម្រាប់មនុស្សម្នាក់)

៣. សក្តានុពលក្នុងការប្តូរឥន្ធនៈ (តម្លៃដាច់ខាតអាចគណនាដោយប្រើប្រពលភាព $CO_2$ ៖ (តោន/ពាន់ដុល្លារ ឆ្នាំ 1995) ។

ការវាយតម្លៃសមត្ថភាពនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន មានបង្ហាញជូននៅក្នុងជួរឈរចុងក្រោយ របស់តារាងទី ៤ ។

តារាងទី ៤ បង្ហាញថា សមត្ថភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅប្រទេសកម្ពុជា និងឡាវ មានតិចតួចបំផុត ហើយនៅប្រទេសវៀតណាម មានមធ្យម ។ ទោះជាយ៉ាងណាក្តី កំណើននៃអត្រាប្រើប្រាស់ថាមពលនៅពេលអនាគតអាចនឹងធ្វើឱ្យតួលេខនេះប្រែប្រួល ។

*តារាងទី ៤. សមត្ថភាពនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (ទិន្នន័យសម្រាប់ឆ្នាំ 2002)*

| ប្រទេស | បរិមាណ $CO_2$ ដែលបញ្ចេញសរុប | | ប្រពលភាពថាមពល | | ប្រពលភាពកាបូន | | **សមត្ថភាពកាត់បន្ថយការបញ្ចេញឧស្ម័ន** |
|---|---|---|---|---|---|---|---|
| | % ធៀបទៅនឹងការបញ្ចេញឧស្ម័នលើពិភពលោក | សក្តានុពលក្នុងការកាត់បន្ថយការបញ្ចេញស្ម័ន | ធៀបនឹងតម្លៃរបស់អាមេរិច 3.1 kWh/ $1995 (100%) | សក្តានុពលក្នុងការលើកកំពស់ប្រសិទ្ធភាពថាមពល | ធៀបនឹងតម្លៃរបស់អាមេរិច 0.63 តោន/ពាន់ $1995 (100%) | សក្តានុពលក្នុងការប្តូរឥន្ធនៈ | |
| កម្ពុជា | 0,022 | ទាបណាស់ | 19,4 | ទាបណាស់ | 22 | ទាប | **ទាប** |
| ឡាវ | 0,015 | ទាបណាស់ | 142 | ខ្ពស់ | 24 | ទាប | **ទាប** |
| វៀតណាម | 0,2 | ទាប-មធ្យម | 248 | ខ្ពស់ណាស់ | 61 | ទាប | **មធ្យម** |
| *ឥណ្ឌូនេស៊ី* | *1,2* | *ខ្ពស់ណាស់* | *192* | *ខ្ពស់* | *217* | *ខ្ពស់ណាស់* | ***ខ្ពស់ណាស់*** |
| *ថៃ* | *0,7* | *ខ្ពស់* | *152* | *ខ្ពស់* | *161* | *ខ្ពស់* | ***ខ្ពស់*** |

*ប្រភព ៖ ស្ថិតិថាមពលផ្លូវការពីរដ្ឋាភិបាលសហរដ្ឋអាមេរិច*

## ២. វិធីសាស្ត្រពីក្រោម-ទៅលើ ៖ សក្តានុពល CDM តាមវិស័យនានា

វិធីសាស្ត្រពីលើ-ចុះក្រោម ដែលបានយកមកប្រើនៅក្នុងផ្នែកខាងលើ ពុំអាចឆ្លុះបញ្ចាំងឱ្យឃើញដោយសុក្រឹត នូវសក្តានុពលនៃការអភិវឌ្ឍ CDM របស់ប្រទេសបានទេ ពីព្រោះថា វិធីសាស្ត្របែបនេះពុំបានយកមកពិចារណានូវកត្តាសំខាន់ៗផ្សេងទៀត ដែលកំណត់នូវភាពទាក់ទាញរបស់សំណើគំរោង CDM ណាមួយ នៅក្នុងទីផ្សារកាបូនពិភពលោក ។ ឧទាហរណ៍ ដូចជាតួនាទីកំណត់នៃការចំណាយលើការកាត់បន្ថយដោយប្រៀបធៀប ជាដើម ។ CDM គឺជាសកម្មភាពដែលផ្អែកលើគំរោង ។ បណ្តាគំរោង CDM ដែលមានសិទ្ធិទទួល រួមបញ្ចូលនូវសកម្មភាពនានាជាច្រើន ព្រមទាំងប្រទេសម្ចាស់ផ្ទះដែលមានសក្តានុពល ។ នៅពេលពិនិត្យតម្លៃលើការកាត់បន្ថយឧស្ម័នរបស់គំរោង CDM គេអាចសង្កេតឃើញនូវភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងវិស័យផ្សេងៗ ។ ជាធម្មតា គេប្រើខ្សែកោងតម្លៃឯកតាបន្ថែមនៃការកាត់បន្ថយ ជាលក្ខណ-វិនិច្ឆ័យដំបូង សម្រាប់ចាត់អាទិភាពបណ្តាជំរើសកាត់បន្ថយរបស់ប្រទេសណាមួយ (ជំហានទី ២ នៅក្នុងរូបទី ១) ។ក៏ប៉ុន្តែ អាចមានករណីខ្លះ ដែលជំរើស CDM មានតម្លៃថោកមួយ ដែលកំណត់នៅក្នុងប្រទេសម្ចាស់ផ្ទះ នឹងមិនត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីនៃគំរោង CDM ដែលគេចូលចិត្ត ដែលអាចផ្តល់នូវឥណទានមានតម្លៃទាបជាងគេ នៅក្នុងទីផ្សារ CDM ពិភពលោក ។ ជាឧទាហរណ៍ ជំរើសបំផ្លាញ HFC-23 ពីផលិតកម្ម HCFC-22 ពុំត្រូវបានគេលើកឡើងទេ នៅក្នុងប្រទេសទាំងបី ។ អាស្រ័យហេតុនេះ គំនិតស្តីពីគំរោង CDM ដែលមានតម្លៃទាប ហើយដែលត្រូវបានគេផ្តល់អាទិភាព នៅក្នុងប្រទេសណាមួយ អាចនឹងមិនអនុវត្តបានតាមបែបសេដ្ឋកិច្ច នៅលើទីផ្សារអន្តរជាតិ ។

កត្តាមួយទៀត ដែលអាចរារាំងមិនឱ្យជំរើសកាត់បន្ថយណាមួយអាចអនុវត្តបានតាមបែបសេដ្ឋកិច្ច គឺការចំណាយពេលវេលាច្រើនក្នុងការរៀបចំគំរោង ចាប់តាំងពីគំនិតដើមដំបូង រហូតដល់ការអនុវត្តជាក់ស្តែង ។ បទពិសោធន៍ជាក់ស្តែង

ក្នុងការរៀបចំគំរោងបង្ហាញថា រយៈពេលសម្រាប់រៀបចំគំរោង CDM ខ្នាតធំអាចបន្ទាយពីបួន ទៅប្រាំបួនឆ្នាំ ។ កត្តានេះពុំត្រូវបានគេយកទៅពិចារណាទេ នៅក្នុងវិធីសាស្ត្រពីលើ-ចុះក្រោម ។

នៅក្នុងស្ថានភាពជាក់ស្តែង អ្នកវិនិយោគតែងភ្ជាប់អាទិភាពសម្រាប់គំរោង ជាមួយនឹងតម្លៃកាត់បន្ថយទាប (នៅក្នុងមាត្រដ្ឋានពិភពលោក) បរិមាណឧស្ម័នអាចកាត់បន្ថយបានច្រើន និងរយៈពេលរៀបចំគំរោងខ្លីល្មម សំដៅបង្កើននូវអត្រាចំណូលផ្ទៃក្នុង (Internal Rate of Return: IRR) នៃគំរោងវិនិយោគណាមួយ ។

ការប្រឈមមុខគួរឱ្យកត់សំគាល់ផ្សេងទៀត សម្រាប់ធ្វើឱ្យគំរោង CDM ណាមួយអាចដំណើរការបានតាមបែបសេដ្ឋកិច្ច គឺការពិបាកក្នុងការវាយតម្លៃភាពបន្ថែម (additionality) និងការរៀបចំលក្ខខណ្ឌគោលសម្រាប់ប្រភេទគំរោងណាមួយ ។ ឧបសគ្គដែលជៀសពុំរួចទាំងនេះជះឥទ្ធិពលយ៉ាងខ្លាំងដល់ការចំណាយរួមរបស់គំរោង CDM ណាមួយ ។ ដូច្នេះវាក៏នឹងមានឥទ្ធិពលផងដែរលើសេចក្តីសម្រេចរបស់អ្នកវិនិយោគ CDM ។ ការប្រឈមមុខទាំងក៏នេះពុំត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងវិធីសាស្ត្រពីលើ-ចុះក្រោមដែរ ។

និន្នាការទីផ្សារកាបូនបច្ចុប្បន្ន បង្ហាញឃើញច្បាស់ថា អ្នកវិនិយោគ និងអ្នកទិញ CER ចូលចិត្តតែគំរោង CDM ណាដែលអាចផ្តល់នូវ CER ច្រើន ហើយដែលមានការងាយស្រួលក្នុងការវាយតម្លៃភាពបន្ថែម និងការគណនាលក្ខខណ្ឌគោល ដូចជាក្នុងករណីការកាត់បន្ថយឧស្ម័នផ្សេងពី $CO_2$ (F-gas, $N_2O$ និង $CH_4$) នៅក្នុងរោងចក្រដែលមានស្រាប់ ។ រូបទី ៥ បង្ហាញពីការចាប់អារម្មណ៍ដោយឡែកសម្រាប់ប្រភេទគំរោង CDM ផ្សេងៗ ។

ភាពលើសលុបនៃគំរោង CDM ដែលកាត់បន្ថយឧស្ម័នផ្សេងពី $CO_2$ ជាករណីមិនអាចជៀសវាងបានឡើយ យ៉ាងហោចណាស់ ក៏នៅក្នុងរយៈពេលខ្លី និងរយៈពេលមធ្យមដែរ ។ ប្រភេទគំរោង CDM ដែលមានច្រើនជាងគេរបស់ប្រទេសជាម្ចាស់ផ្ទះ នឹងមានឥទ្ធិពលលើភាពប្រកួតប្រជែងរបស់ប្រទេសនៅលើទីផ្សារ ។ ជាទូទៅ វិធីសាស្ត្រពីលើ-ចុះក្រោមពុំអាចដាក់បញ្ចូលនូវបណ្តាកត្តាទីផ្សារទាំងនេះ ទៅក្នុងការវាយតម្លៃសក្តានុពលសម្រាប់អភិវឌ្ឍគំរោង CDM បានទេ ។

ដោយសារហេតុផលនេះ យើងនឹងប្រើវិធីសាស្ត្រពីក្រោម-ទៅលើ បន្ថែមលើការវាយតម្លៃតាមវិធីសាស្ត្រពីលើ-ចុះក្រោម ដើម្បីផ្តល់នូវការវាយតម្លៃគ្រប់ជ្រុងជ្រោយ ស្តីពីសមត្ថភាព CDM របស់ប្រទេសណាមួយ ។ កាលានុវត្តភាព CDM តាមវិស័យ នៅក្នុងបណ្តាប្រទេសទាំងបីដែលលើកយកមកសិក្សា ក៏នឹងត្រូវបានវាយតម្លៃដែរ ។

លទ្ធផលមានបង្ហាញជូននៅក្នុងតារាងទី ៥ ។ ទិន្នន័យសម្រាប់ការវាយតម្លៃ ត្រូវបានយកមកពីការសិក្សានៅកម្ពុជាក្រោមគំរោង CD4CDM ឯនៅវៀតណាមត្រូវបានយកមកពីការសិក្សាក្រោមគំរោង ALGAS, NSS ដោយផ្សំជាមួយនឹងការវាយតម្លៃដោយផ្ទាល់របស់យើង ។ មកទល់បច្ចុប្បន្ន យើងពុំអាចរកបានឡើយនូវការសិក្សាស្រដៀងគ្នាដើម្បីគូរខ្សែកោងតម្លៃបន្ថែមសម្រាប់ប្រទេសឡាវ ។ អាស្រ័យហេតុនេះ បណ្តាជំរើសកាត់បន្ថយសម្រាប់ប្រទេសឡាវត្រូវបានផ្អែកលើការប៉ាន់ស្មានប្រហាក់ប្រហែលរបស់អ្នកជំនាញការ ។

ជាការពិត ប្រទេសទាំងបីមានជំរើសកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលជាទូទៅនៅក្នុងវិស័យថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ។ ពិតមែនតែប្រភេទគំរោងបែបនេះតែងត្រូវបានគេប្រទះឃើញញឹកញាប់ជាងគេក្តី ក៏បណ្តាគំរោងបែបនេះផលិតឥណទានកាបូនតែប្រមាណ 25% ប៉ុណ្ណោះ នៃឥណទានកាបូនទាំងអស់ ដែលផលិតចេញពី CDM (ទិន្នន័យយកពីគេហទំព័ររបស់ UNFCCC គិតត្រឹមថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៥) ។ ប្រការនេះបង្ហាញឱ្យ

ឃើញថា "ទីផ្សារនឹងខិតខំរកនូវតំណទានដែលមានតម្លៃថោកជាងគេ តែមិនមែនលទ្ធផលដែលល្អប្រសើរបំផុតផ្នែកបរិស្ថានឡើយ" (Pearson, 2005) ។ និន្នាការនេះប្រហែលនឹងនៅបន្តនៅបណ្ដាឆ្នាំខាងមុខទៀត ប្រសិនបើពុំមានសម្ពាធឱ្យអនុវត្ត CDM ដោយខានពុំបាន ថាជាយន្តការមួយសម្រាប់នាំមកនូវផលប្រយោជន៍អភិវឌ្ឍន៍ដោយចីរភាពបន្ថែម ដល់ប្រទេសជាម្ចាស់ផ្ទះ ហើយសម្ពាធនេះនឹងខ្លាំងគ្រប់គ្រាន់ ដែលអាចធ្វើឱ្យអ្នកវិនិយោគធ្វើការពិចារណាជ្រើសរើសយកថាមពលកកើតឡើងវិញ ។

ដូច្នេះ ការកាត់បន្ថយការបញ្ចេញឧស្ម័នពីបណ្ដាប្រភេទគំរោងដែលមានច្រើនលើសលុបបែបនេះ នៅក្នុងប្រទេសទាំងបី នឹងប្រហែលជាប្រឈមមុខជាមួយនឹងការប្រកួតប្រជែងអន្តរជាតិដ៏ខ្លាំងក្លា ។ និយាយម្យ៉ាងទៀត ដោយពិចារណាលើកត្តាសំខាន់ៗដែលកំណត់នូវភាពអាចសម្រេចបាននៃការប្រែក្លាយបណ្ដាជំរើសកាត់បន្ថយឱ្យទៅជាការវិនិយោគ CDM តារាងទី ៥ បង្ហាញថា ភាគច្រើននៃបណ្ដាជំរើសទាំងនេះប្រហែលជានឹងពុំអាចជាជំរើស CDM ដែលមានភាពទាក់ទាញឡើយ នៅលើទីផ្សារ CDM អន្តរជាតិ ក្នុងបណ្ដាឆ្នាំខាងមុខនេះ ។




*ប្រភព៖ ទិន្នន័យពីគេហទំព័ររបស់ UNFCCC គិតត្រឹមថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៥. គំរោងដែលបានដាក់ជូនរួចហើយ*

*រូបទី ៥. ចំណែកថ្នាក់ប្រភេទគំរោង CDM ដោយផ្អែកលើឥណទានប្រចាំឆ្នាំ និងចំនួនគំរោង*

*តារាងទី ៥. កាលានុវត្តភាពCDM តាមវិស័យ*

| ជំរើសកាត់បន្ថយ | តម្លៃ CER | បរិមាណកាត់បន្ថយ | ការពិបាកក្នុងការវាយតម្លៃភាពបន្ថែម និងលក្ខខណ្ឌគោល | រយៈពេល | កម្ពុជា | ឡាវ | វៀតណាម |
|---|---|---|---|---|---|---|---|
| **ប្រសិទ្ធភាពថាមពល** | | | | | | | |
| ឆ្នាំងចំហាយឧស្សាហកម្ម | ទាប | ទាប-មធ្យម | មធ្យម | ទាប | -- | -- | xx |
| ផលិតកម្មស៊ីម៉ងត៍ (លាយជាមួយឥន្ធនៈប្រើហើយ) | ទាប | មធ្យម | មធ្យម | មធ្យម | -- | -- | x |
| ការជំនួសអំពូលពងមាន់ដោយអំពូលម៉ែត | ទាប | ទាប-មធ្យម | មធ្យម | មធ្យម | x | x | x |
| ចង្ក្រានចំអិនអាហារ | ទាប | ទាប | មធ្យម-ខ្ពស់ | មធ្យម | x | x | xx |
| ការសន្សំសំចៃថាមពលនៅក្នុងអគារ | ទាប | ទាប | មធ្យម | មធ្យម | x | x | xx |
| ការចាប់យកកំដៅសំណល់ពីឧស្សាហកម្មធុនធ្ងន់ (ឧស្សាហកម្មដែកថែប ក្រដាស) | ទាប | មធ្យម | មធ្យម | មធ្យម | -- | -- | x |
| **ប្រសិទ្ធភាពថាមពល - ការផលិតអគ្គិសនី** | | | | | | | |
| ការកែលំអ និងទំនើបកម្មផ្នែកកំដៅ | ខ្ពស់ | មធ្យម-ខ្ពស់ | មធ្យម | ទាប-មធ្យម | -- | -- | xx |
| ការផលិតអគ្គិសនី និងកំដៅរួមគ្នា | ទាប | មធ្យម | មធ្យម | មធ្យម | x | x | xx |

x: ខ្នាតតូច xx: ខ្នាតមធ្យម xxx: ខ្នាតធំ -- ពុំមាន

*តារាងទី ៥. កាលានុវត្តភាពCDM តាមវិស័យ (ត)*

| ជំរើសកាត់បន្ថយ | តម្លៃ CER | បរិមាណកាត់បន្ថយ | ការពិបាកក្នុងការវាយតម្លៃភាពបន្ថែម និងលក្ខខណ្ឌគោល | រយៈពេល | កម្ពុជា | ឡាវ | វៀតណាម |
|---|---|---|---|---|---|---|---|
| **ថាមពលកកើតឡើងវិញ** | | | | | | | |
| ថាមពលខ្យល់ | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | -- | -- | x |
| រោងចក្រវារីអគ្គិសនីធុនតូច | ទាប-មធ្យម | ទាប | ខ្ពស់ | មធ្យម | x | x | xx |
| រោងចក្រវារីអគ្គិសនីធុនធំ | មធ្យម | ខ្ពស់ | ខ្ពស់ | ខ្ពស់ | -- | xx | xx |
| ថាមពលព្រះអាទិត្យ | ខ្ពស់ណាស់ | ទាប | ខ្ពស់ | មធ្យម | x | x | xx |
| រោងចក្រថាមពលកំដៅក្នុងដី | មធ្យម-ខ្ពស់ | មធ្យម-ខ្ពស់ | ខ្ពស់ | ខ្ពស់ | x | -- | x |
| ជីវៈម៉ាស | ទាប-មធ្យម | មធ្យម | ខ្ពស់ | មធ្យម | x | x | xx |
| **ការដឹកជញ្ជូន** | | | | | | | |
| ការប្តូរឥន្ធនៈ | មធ្យម | ទាប-មធ្យម | ខ្ពស់ | មធ្យម | -- | -- | x |
| ការដឹកជញ្ជូនសាធារណៈ | ខ្ពស់ | ទាប | ខ្ពស់ | មធ្យម | x | x | x |

x: ខ្នាតតូច xx: ខ្នាតមធ្យម xxx: ខ្នាតធំ -- ពុំមាន

*តារាងទី ៥. កាលានុវត្តភាពCDM តាមវិស័យ (ត)*

| ជំរើសកាត់បន្ថយ | តម្លៃ CER | បរិមាណកាត់បន្ថយ | ការពិបាកក្នុងការវាយតម្លៃភាពបន្ថែម និងលក្ខខណ្ឌគោល | រយៈពេល | កម្ពុជា | ឡាវ | វៀតណាម |
|---|---|---|---|---|---|---|---|
| **ការត្រួតពិនិត្យការបញ្ចេញឧស្ម័នគេច** | | | | | | | |
| ឧស្ម័នពីទីលានចាក់សំរាម (LFG) | ទាប | មធ្យម-ខ្ពស់ | ទាប | | x | x | xx |
| ឧស្ម័នដែលភាយចេញពីផលិតកម្មប្រេង | ទាប | ខ្ពស់ណាស់ | ទាប | មធ្យម | -- | -- | xx |
| ការចាប់យកមេតានពីសំណល់កសិកម្ម | មធ្យម | មធ្យម-ខ្ពស់ | ខ្ពស់ | មធ្យម | x | x | xx |
| មេតានចេញពីអណ្តូងរ៉ែធ្យូងថ្ម | ទាប | ខ្ពស់ | ទាប | មធ្យម | -- | -- | x |
| **ឧស្ម័នឧស្សាហកម្ម** | | | | | | | |
| អាស៊ីតនីទ្រិច $N_2O$ | ទាបណាស់ | ខ្ពស់ | ទាប | មធ្យម | -- | -- | x |
| អាលុយមីញ៉ូម PFC | ទាប | ខ្ពស់ | មធ្យម | មធ្យម | -- | -- | x |
| អាស៊ីតអាឌីពិច $N_2O$ | ទាបណាស់ | ខ្ពស់ណាស់ | ទាប | មធ្យម | -- | -- | x |
| HFC 23 | ទាបណាស់ | ខ្ពស់ណាស់ | ទាប | មធ្យម | -- | -- | -- |

x: ខ្នាតតូច xx: ខ្នាតមធ្យម xxx: ខ្នាតធំ -- ពុំមាន

សរុបសេចក្តីទៅ បរិបទថាមពលរបស់ប្រទេសកម្ពុជា និងឡាវមានភាពស្រដៀងគ្នា បើនិយាយពីអត្រាប្រើប្រាស់ទាប និងនិន្នាការអភិវឌ្ឍន៍ ។ ប្រទេសទាំងពីរមានសក្តានុពលសម្រាប់គំរោង CDM ខ្នាតតូច ដូចជាវារីអគ្គិសនីធុនតូច សំណល់ទីក្រុងនិងសំណល់កសិកម្មតូចៗ និងប្រសិទ្ធភាពថាមពលសម្រាប់ឧបករណ៍ប្រើប្រាស់ ។ យោងទៅតាមទស្សនៈនៃការអភិវឌ្ឍ បណ្តាគំរោងទាំងនេះអាចផ្តល់ប្រយោជន៏ដល់សហគមន៏មូលដ្ឋាន ដោយសារតែវាអាចដោះស្រាយបញ្ហាបរិស្ថាននៅមូលដ្ឋាន ហើយជួយកាត់បន្ថយការបញ្ចេញឧស្ម័ន ។ ក៏ប៉ុន្តែ ដូចដែលការអនុវត្តជាក់ស្តែងបានបង្ហាញឱ្យឃើញ ប្រភេទគំរោង CDM ទាំងនេះប្រហែលជាពុំមានភាពទាក់ទាញខ្លាំងសម្រាប់អ្នកវិនិយោគកាបូនទេ យ៉ាងហោចណាស់ក៏សម្រាប់ដំណាក់កាលទី ១ នៃកាតព្វកិច្ចដែរ ។ ក៏រិតហានិភ័យខ្ពស់ និងការចំណាយលើមុខជំនួញដែលពាក់ព័ន្ធខ្ពស់ បានដាក់ឱ្យគំរោងបែបនេះស្ថិតនៅក្នុងភាពចាញ់ប្រៀប ក្នុងការប្រកួតប្រជែង ដើម្បីហិរញ្ញប្បទានកាបូន ។

ដោយយោងទៅលើករណីជាក់ស្តែងនៅកម្ពុជា និងឡាវ ព្រមទាំងប្រភេទគំរោងដែលគេនិយមបច្ចុប្បន្ននៅក្នុង CDM យើងឃើញថា ប្រទេសទាំងពីរនឹងជួបការប្រឈមមុខយ៉ាងលំបាក ក្នុងការស្វែងរកទីតាំង ដើម្បីឈានជើងចូលទៅក្នុងទីផ្សារកាបូន ។

ប្រទេសវៀតណាមមានភាពខុសគ្នាច្រើន ធៀបជាមួយកម្ពុជា និងឡាវ បើនិយាយអំពីការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ពោលគឺវៀតណាមស្ថិតនៅក្នុងទីតាំងមួយប្រសើរជាង ។ លើសពីនេះ ភាពអំណោយផលផ្នែក CDM របស់វៀតណាមក៏មានលក្ខណៈចម្រុះ ហើយមានភាពប្រកួតប្រជែងជាង ផ្នែកបរិមាណ ។ ទោះជាយ៉ាងណាក្តី ប្រទេសនេះក៏ពុំមានចំនួនជំរើសកាត់បន្ថយច្រើនដែរ ដែលអាចប្រែក្លាយទៅជាគំរោងមានគុណភាព និងបរិមាណខ្ពស់ (>100.000 CERs) នៅក្នុងបណ្តាវិស័យដែលអ្នកវិនិយោគនិយម ដូចមានបង្ហាញនៅក្នុងតារាងទី ៥ ។ ដោយសារតែកម្លាំងចលករសម្រាប់លើកស្ទួយការវិនិយោគនៅមានក៏រិត នោះប្រហែលជាពុំមានលំហូរវិនិយោគផ្នែក CDM ចូលទៅក្នុងប្រទេសវៀតណាមច្រើនណាស់ណាទេ យ៉ាងហោចណាស់ក៏នៅក្នុងដំណាក់កាលទី ១ នៃកាតព្វកិច្ចដែរ ។

## ៣. បរិស្ថានវិនិយោគរបស់ប្រទេស

### ៣.១ បរិស្ថានវិនិយោគ និងភាពទាក់ទាញសម្រាប់ការវិនិយោគ CDM

បរិស្ថានវិនិយោគគឺជាកត្តាគន្លឹះមួយទៀត ដែលកំណត់នូវភាពទាក់ទាញរបស់ប្រទេសមួយ សម្រាប់ការវិនិយោគ CDM ។ ជាធម្មតា គេពិចារណាភាពអនុគ្រោះនេះ ដោយផ្អែកលើភាពទាក់ទាញនៃបរិស្ថានវិនិយោគទូទៅ និងក៏រិតនៃហានុភ័យផ្នែកហិរញ្ញវត្ថុ និងផ្នែកវិនិយោគដែលពាក់ព័ន្ធ ។

វិនិយោគបរទេសផ្ទាល់ (Foreign direct investment: FDI) គឺជារង្វាស់ដ៏ទូលំទូលាយមួយ ហើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយស្ថានភាពទូទៅនៃបរិស្ថានវិនិយោគរបស់ប្រទេស ។ FDI ដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ស្ទើរតែទាំងអស់ ។ FDI បង្ហាញពីទំនាក់ទំនងដែលអាចកើតមាន រវាងបណ្តាប្រភេទនៃលក្ខខណ្ឌអនុគ្រោះនានាដែលទាក់ទាញ FDI ព្រមទាំងពីលទ្ធភាពទទួលបានជោគជ័យក្នុងការបង្កើត និងប្រើប្រាស់នូវ CDM ។

ការវិភាគលើលំហូរ និងជំនួយអភិវឌ្ឍន៍ផ្លូវការ (Official development assistance: ODA) ព្រមទាំងលើការវិនិយោគ CDM ដែលមានសក្តានុពល បង្ហាញថា ជាញឹកញាប់ប្រទេសដែលអាចផលិតឥណទានច្រើនពីគំរោង CDM ដែលស្មើឡើង ច្រើនតែជាប្រទេសដែលទទួលនូវលំហូរ FDI ក្នុងសមាមាត្រច្រើនដែរ (Ellis *et al.*, 2004) ។

លំហូរ FDI មានភាពសម្រាំង ពោលគឺវាហូរចូលតែទៅក្នុងប្រទេស ឬកន្លែងណាដែលមានលក្ខខណ្ឌអនុគ្រោះសម្រាប់ការវិនិយោគ ។ លក្ខខណ្ឌអនុគ្រោះទាំងនេះរួមមាន របបនយោបាយមានស្ថេរភាព បរិស្ថានច្បាប់រឹងមាំសម្រាប់ការធ្វើកិច្ចសន្យា សមត្ថភាពអនុវត្តច្បាប់ល្អ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ភាពអាចរកបាននូវកម្មករមានជំនាញ និងធនធានមនុស្សផ្សេងទៀត ។ ដោយសារតែប្រទេសកំពុងអភិវឌ្ឍក្រីក្រជាងគេភាគច្រើនពុំមាននូវលក្ខខណ្ឌអភិបាលកិច្ចជាមូលដ្ឋាន ដើម្បីទាក់ទាញ FDI នោះ ODA នឹងនៅតែជាប្រភពហិរញ្ញប្បទានដ៏សំខាន់មួយ សម្រាប់ការផ្ទេរបច្ចេកវិទ្យា នៅក្នុងបណ្តាប្រទេសទាំងនេះនាពេលអនាគតខាងមុខ (Ellis *et al.*, 2004) ។

នៅក្នុងជំពូកនេះ យើងវាយតម្លៃបរិស្ថានវិនិយោគរបស់ប្រទេសទាំងបី និងភាពជាប់ជំពាក់ជំពិនរបស់វា សម្រាប់លំហូរជាសក្តានុពលនៃ CDM នៅក្នុងប្រទេសទាំងនេះ ។

### ៣.២ បរិស្ថានវិនិយោគនៅកម្ពុជា ឡាវ និងវៀតណាម

ប្រទេសកម្ពុជា ឡាវ និងវៀតណាម បានបើកទ្វារចំហរដល់វិនិយោគបរទេសចាប់ពីចុងទសវត្សរ៍ឆ្នាំទី 80 មក ។ ក្នុងខណៈដែលតំបន់អាស៊ីភាគអាគ្នេយ៍បានលេចឡើងជាគោលដៅមួយសម្រាប់ FDI នោះ យើងឃើញថាលំហូរ FDI ចូលទៅក្នុងប្រទេសទាំងបីបានកើនឡើងដល់ 4.390 លានដុល្លារអាមេរិច នៅឆ្នាំ 1997 ។ ជាប្រការគួរឱ្យស្តាយ ឆ្នាំ 1997 នោះគឺជាឆ្នាំដែលលំហូរ FDI ទៅក្នុងអនុតំបន់នេះ បានកើនឡើងខ្ពស់បំផុត មកទល់សព្វថ្ងៃ (រូបទី ៦) ។ ការធ្លាក់ចុះនៃលំហូរ FDI គឺមួយភាគធំបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុនៅអាស៊ី នៅពាក់កណ្តាលឆ្នាំ 1997 ។ ក៏ប៉ុន្តែ មូលហេតុសំខាន់ ដែលជះឥទ្ធិពលដល់លំហូរ FDI ចូលទៅក្នុងប្រទេសទាំងបី ក្នុងរយៈពេលវែង អាចជាការធ្លាក់ចុះនៃសេចក្តីរំពឹងទុករបស់

អ្នកវិនិយោគ ។ ការប៉ាន់ស្មានលើសអំពីកំណើននៅក្នុងតំបន់នេះត្រូវបានថយចុះ ដោយសារតែអ្នកវិនិយោគបរទេសបានជួបប្រទះនឹងឧបសគ្គជាដុំកំភួន នៅពេលអនុវត្តគំរោង FDI នៅតណ្ឌចិន ។

បន្ទាប់ពីសង្គ្រាមរាប់ទសវត្សរ៍មក កម្ពុជាបានសម្រេចបាននូវជោគជ័យជាច្រើនក្នុងអន្តរកាលឆ្ពោះទៅសេដ្ឋកិច្ចទីផ្សារសេរី ។ ក៏ប៉ុន្តែ ប្រទេសនេះនៅតែពឹងអាស្រ័យយ៉ាងខ្លាំងទៅលើជំនួយបរទេស ។ នៅឆ្នាំ 2001 ប្រមាណ 58% នៃថវិការដ្ឋាភិបាលកណ្តាលបានមកពីជំនួយបរទេស ។ ប្រទេសកម្ពុជាបានជួបប្រទះនឹងការលំបាកក្នុងការទាក់ទាញ FDI ដោយសារតែបរិស្ថានច្បាប់នៅមិនទាន់មាំទាំ ។ ក៏រិត FDI ថ្មីបានធ្លាក់ចុះ ចាប់តាំងពីឆ្នាំ 1997 មក ។ វិនិយោគបរទេសបានប្រមូលផ្តុំនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងវាយនភណ្ឌ ដែលរួមចំណែកប្រមាណជា 90% នៃការនាំចេញរបស់ប្រទេស ។




*ប្រភព ៖ លេខាធិការដ្ឋានអាស៊ាន - ASEAN FDI Database, 2004*

*រូបទី ១. ប្រចាំឆ្នាំរបស់កម្ពុជា ឡាវ និងវៀតណាម 1997 - 2003*

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវគឺជាប្រទេសក្របំផុតទីពីរ (បន្ទាប់ពីកម្ពុជា) នៅអាស៊ីខាងកើត ។ រដ្ឋាភិបាលប្រទេសនេះបានក្លាយទៅជាពឹងអាស្រ័យទាំងស្រុងលើជំនួយបរទេស ។ បន្ទាប់ពីការរីកចំរើនផ្នែកសេដ្ឋកិច្ច និងកំណែទម្រង់អស់រយៈពេល 8 ឆ្នាំមក ដំណើរការនេះក៏បានចុះយឺតយ៉ាវនៅឆ្នាំ 1998 ។ ជំនឿទុកចិត្តទាបនៅក្នុងសេដ្ឋកិច្ចឡាវ បរិស្ថានវិនិយោគទន់ខ្សោយជាទូទៅ និងហេដ្ឋារចនាសម្ព័ន្ធចាស់ បានធ្វើឱ្យប្រទេសក្នុងទ្វីបមួយនេះជួបការលំបាកយ៉ាងខ្លាំង ក្នុងការទាក់ទាញ FDI ។ នាពេលថ្មីៗនេះ អ្នកវិនិយោគជាច្រើន (ជាពិសេសជនជាតិថៃ) បានចាកចេញពីឡាវ ។ ការអនុម័តលើ FDI នៅប្រទេសឡាវបានធ្លាក់ចុះពីកំរិតខ្ពស់បំផុតចំនួន 2,6 ពាន់លានដុល្លារអាមេរិច នាឆ្នាំ 1995 មកនៅត្រឹមតែ 25 លានដុល្លារអាមេរិច នៅឆ្នាំ 2004 ។ គំរោងទំនប់វារីអគ្គិសនីរួមចំណែកច្រើនជាងគេនៅក្នុង FDI ហើយវិស័យនេះប្រហែលជានឹងទាក់ទាញវិនិយោគទុនបរទេសច្រើនជាងគេ (ធនាគារឡាវ 2005) ដែលអាចបើកច្រកដល់ការវិនិយោគ CDM ។

យោងតាម AT Kearney (2004) ប្រទេសវៀតណាមបានក្លាយទៅជាគោលដៅវិនិយោគដែលគេចូលចិត្តជាងគេទី 21 នៅលើពិភពលោក ។ សមាសភាគដ៏សំខាន់មួយនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងរបស់ប្រទេសនេះ គឺលទ្ធភាពដែលមានជាប្រចាំក្នុងការទាក់ទាញ និងប្រើប្រាស់នូវមូលធនក្រៅប្រទេសយ៉ាងច្រើនក្រាស់ក្រែល ទាំង FDI ក៏ដូចជា ODA ។ នៅក្នុងន្លោះឆ្នាំ 2001-2005 រដ្ឋាភិបាលវៀតណាមបានដាក់ចុះនូវគោលដៅសម្រាប់ FDI ចំនួន 11 ពាន់លានដុល្លារអាមេរិច សម្រាប់វិនិយោគបរទេសដែលមានស្រាប់ និងដែលទើបបានទទួលអាជ្ញាបណ្ណថ្មី ហើយក៏បានដាក់ចុះនូវគោលដៅសម្រាប់ ODA ចំនួន 10-11 ពាន់លានដុល្លារអាមេរិច ដែលត្រូវចំណាយដោយអ្នកផ្តល់ជំនួយបរទេស ។ កំរិតប៉ាន់ស្មាននៃ FDI និង ODA នេះ ជាលក្ខខណ្ឌសម្រាប់ទ្រទ្រង់ដល់កំណើន GDP របស់រដ្ឋាភិបាលចំនួន 7,5% ក្នុងមួយឆ្នាំ ។ មកទល់ខែធ្នូ ឆ្នាំ 2004 វៀតណាមបានទាក់ទាញវិនិយោគចំនួនប្រមាណ 46 ពាន់លានដុល្លារអាមេរិច ។

ទោះជាយ៉ាងណាក្តី ក៏នៅមានឧបសគ្គចំបងជាច្រើនទៀត ដែលរារាំងដល់អ្នកវិនិយោគបរទេស ។ ឧបសគ្គចំបងៗជាងគេដែលកំរិតសក្តានុពល FDI របស់វៀតណាមរួមមាន ហេដ្ឋារចនាសម្ព័ន្ធពុំសមស្រប ដំណើរការយឺតយាវនៃឯកជនភាវូ-បនីយកម្មសហគ្រាសរដ្ឋ និងកង្វះខាតសមត្ថភាពផ្នែករដ្ឋបាល និងផ្នែកស្ថាប័ន ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចទីផ្សារ ។




*ប្រភព ៖ សៀវភៅស្ថិតិប្រចាំឆ្នាំរបស់ ASEAN, 2004*

*រូបទី ៧. លំហូរ FDI ចូលទៅក្នុងអាស៊ាន តាមប្រទេសម្ចាស់ផ្ទះ សម្រាប់ឆ្នាំ 1995-2003*

រូបទី ៧ បង្ហាញយ៉ាងច្បាស់អំពីទីតាំងបន្ទាប់បន្សំរបស់កម្ពុជា និងឡាវ នៅក្នុងផែនទីលំហូរ FDI នៃតំបន់ គិតជាតម្លៃដាច់ខាត ។ ពិតមែនតែវៀតណាមស្ថិតនៅក្នុងលំដាប់ថ្នាក់លេខបួន ក្នុងចំណោមប្រទេសដែលបានទទួល FDI ខ្ពស់ជាងគេក្តី ក៏យើងឃើងថា មានចន្លោះប្រហោងធំសម្បើមរវាងប្រទេសនេះ និងប្រទេសថៃ ដែលជាប់លេខបី ។

ដើម្បីគូសបញ្ជាក់អំពីទីតាំងធៀបរបស់បណ្តាប្រជាជាតិអាស៊ាន ឱ្យបានរិតតែគ្រប់ជ្រុងជ្រោយ វិទ្យាស្ថានសិក្សាគោលនយោបាយ (Tan Khee Giap *et al.*, 2005) បានរៀបចំ "សន្ទស្សន៍ចំណែកថ្នាក់ភាពប្រកួតប្រជែងប្រចាំឆ្នាំ IPS ASEAN 9+1 " ដើម្បីចាត់ថ្នាក់ប្រទេសអាស៊ានទាំងប្រាំបួន ដោយផ្អែកលើកក្រុមសន្ទស្សន៍សំខាន់បួន (តារាងទី ៦) ៖

*តារាងទី ៦ ៖ ចំណែកថ្នាក់ភាពប្រកួតប្រជែងរបស់អាស៊ាន*

| ប្រទេស | សរុប | បរិស្ថានសេដ្ឋកិច្ច | បរិស្ថាននយោបាយ | បរិស្ថានជំនួញ | បរិស្ថានសង្គម |
|---|---|---|---|---|---|
| សិង្ហបុរី | 1 | 1 | 1 | 1 | 1 |
| ម៉ាឡេស៊ី | 2 | 3 | 2 | 2 | 2 |
| ថៃ | 3 | 2 | 3 | 3 | 3 |
| ហ្វីលីពីន | 4 | 4 | 4 | 4 | 4 |
| **វៀតណាម** | **5** | **6** | **6** | **5** | **5** |
| ឥណ្ឌូណេស៊ី | 6 | 5 | 5 | 6 | 8 |
| **កម្ពុជា** | **7** | **7** | **7** | **7** | **6** |
| មីយ៉ានម៉ា | 8 | 8 | 8 | 8 | 9 |
| **ឡាវ** | **9** | **9** | **9** | **9** | **6** |

*ប្រភព ៖ Tan Khee Giap et al. 2005*

ដូច្នេះ ចំណែកថ្នាក់ភាពប្រកួតប្រជែងអាចពន្យល់ឱ្យដឹងពីអត្រាលំហូរ របស់ប្រទេសទាំងបី នៅក្នុងតំបន់ ដូចមានបង្ហាញនៅក្នុងរូបទី ៧ ។

នៅកំរិតអន្តរជាតិ "របាយការណ៍ពីភាពប្រកួតប្រជែងលើពិភពលោក" ដែលបានបោះពុម្ពផ្សាយដោយវេទិកាសេដ្ឋកិច្ចពិភពលោក បានធ្វើការវាយតម្លៃប្រចាំឆ្នាំនូវភាពប្រកួតប្រជែងរបស់ប្រទេសណាមួយ ដោយផ្អែកលើកត្តាបីយ៉ាង ៖ សន្ទស្សន៍បរិស្ថានម៉ាក្រូសេដ្ឋកិច្ច សន្ទស្សន៍ស្ថាប័នសាធារណៈ និងសន្ទស្សន៍បច្ចេកវិទ្យា ។ នៅក្នុងរបាយការណ៍នេះ ប្រទេសវៀតណាមបានធ្លាក់ចុះពីលំដាប់លេខ 60 នៅឆ្នាំ 2003 រហូតដល់លំដាប់លេខ 77 នៅឆ្នាំ 2004 (វេទិកាសេដ្ឋកិច្ចពិភពលោក) ។ ការណ៍នេះគឺបណ្តាលមកពីការធ្លាក់ចុះយ៉ាងខ្លាំងនៃកត្តាទាំងបីដែលប្រើជាសន្ទស្សន៍ ជាពិសេសគឺស្ថាប័នសាធារណៈ និងបច្ចេកវិទ្យា ។

ជាប្រការគួរឱ្យស្តាយ ប្រទេសកម្ពុជា និងឡាវពុំត្រូវបានគេយកទៅធ្វើចំណាត់ថ្នាក់នៅក្នុងការចាត់ថ្នាក់ប្រចាំឆ្នាំពិភពលោកនេះឡើយ ។ ជាថ្មីម្តងទៀត ប្រការនេះអាចបណ្តាលមកពីទីតាំងបន្ទាប់បន្សំរបស់ប្រទេសទាំងពីរ នៅលើផែនទី FDI របស់ពិភពលោក ។

នៅខែកញ្ញា ឆ្នាំ ២០០៥ ទស្សនាវដ្តី "អ្នកវិនិយោគស្ថាប័ន" បានផ្តល់នូវកំរិតហានុភ័យសម្រាប់ប្រទេសទាំងបីដូចខាងក្រោម ៖

| ប្រទេស | កំរិតហានិភ័យ | ចំណាត់ថ្នាក់ហានិភ័យនៅលើពិភពលោក |
|---|---|---|
| កម្ពុជា | 21,2% | 139 |
| ឡាវ | 24,6% | 125 |
| វៀតណាម | 40,0% | 80 |

ទស្សនាវដ្ដីនេះបានបោះពុម្ពផ្សាយនូវចំណាត់ថ្នាក់ភាពជឿទុកចិត្ត ដោយផ្អែកលើព័ត៌មានដែលផ្ដល់ឱ្យ ដោយបណ្ដាធនាគារអន្តរជាតិធំៗ ក្រុមហ៊ុនគ្រប់គ្រងរូបិយបណ្ណ និងអ្នកសេដ្ឋកិច្ច ។ គេបានប្រើមាត្រដ្ឋានពី 0 ទៅ 100 ដែលក្នុងនោះតួលេខ 100 បង្ហាញនូវកំរិតហានិភ័យតិចបំផុត ។

ប្រសិនបើភាពទាក់ទាញ FDI របស់ប្រទេស បង្ហាញនូវលទ្ធភាពក្នុងការទាក់ទាញការវិនិយោគ CDM នោះគេអាចសន្និដ្ឋានបានថា និន្នាការនៃលំហូរ FDI និងបទពិសោធន៍របស់អ្នកវិនិយោគក្នុងការអនុវត្តគំរោង FDI នៅកម្ពុជា និងឡាវ ហាក់ដូចជាផ្ដល់នូវឧទាហរណ៍ពុំសូវល្អ សម្រាប់ឱ្យអ្នកវិនិយោគ CDM សម្រេចចិត្តធ្វើការវិនិយោគនៅក្នុងប្រទេសទាំងនេះ ។

នៅវៀតណាម លំហូរ FDI ហាក់ដូចជានៅទាបជាងសក្ដានុពលរបស់ប្រទេសនេះនៅឡើយ ។ ឧបសគ្គធំបំផុតគឺការចំណាយខ្ពស់ ដោយសារតែការបន្ដឹងរបស់រដ្ឋាភិបាល ។ រូបភាពមិនអំណោយផលបែបនេះរបស់បរិស្ថានវិនិយោគនៅវៀតណាម អាចជះឥទ្ធិពលអវិជ្ជមាន ដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេស ក្នុងការទាក់ទាញការចាប់អារម្មណ៍របស់អ្នកវិនិយោគ CDM ។

## ៤. ស្ថាប័ន CDM និងបទពិសោធន៍គំរោង CDM របស់ប្រទេស

### ៤.១ ស្ថាប័ន CDM របស់ប្រទេសម្ចាស់ផ្ទះ

ដើម្បីអាចចូលរួមបាននៅក្នុង CDM ប្រទេសម្ចាស់ផ្ទះចាំបាច់ត្រូវបំពេញការងាររៀបចំស្ថាប័នដោយឡែកមួយចំនួន ។ គេអាចបង្កើតស្ថាប័ននានាក្នុងរយៈពេលខ្លី ក៏ប៉ុន្តែគេចាំបាច់ត្រូវការពេលវេលាច្រើនគួរសម ដើម្បីឱ្យប្រព័ន្ធស្ថាប័នថ្មីនេះដំណើរការដោយប្រសិទ្ធភាព និងត្រឹមត្រូវ ។

លទ្ធផលនៃការសិក្សារបស់អ្នកឯកទេស ដែលបានធ្វើឡើងដោយ Point Carbon (2002) ស្តីពីសារៈសំខាន់ធៀប នៃបណ្តាកត្តាដែលមានឥទ្ធិពលលើការវិនិយោគ CDM បានបង្ហាញថា ប្រព័ន្ធអនុម័តគំរោង CDM របស់ប្រទេសដែលមានលក្ខណៈគាំទ្រ គឺជាកត្តាសំខាន់បំផុតមួយ ដែលទាក់ទាញអ្នកវិនិយោគ ។

ប្រព័ន្ធស្ថាប័ន CDM ដែលមានលក្ខណៈទ្រទ្រង់ រួមបញ្ចូលនូវកត្តាមួយចំនួន ដូចតទៅ ៖

- ការបំពេញតាមលក្ខខណ្ឌដំបូងទាំងអស់សម្រាប់ការចូលរួមក្នុង CDM ដូចជា ការផ្តល់សច្ចាប័នដល់ពិធីសារក្យូតូ ការជូនដំណឹងស្តីពីការបង្កើត DNA
- សេចក្តីសម្រេចគោលនយោបាយច្បាស់លាស់ ដោយប្រទេសជាម្ចាស់ផ្ទះ ក្នុងការចូលរួមក្នុង CDM នីតិវិធីប្រកបដោយតម្លាភាព ព្រមទាំងមានស្ថាប័នគ្រប់គ្រាន់ សម្រាប់ការអនុម័តគំរោងដោយរដ្ឋាភិបាលម្ចាស់ផ្ទះ
- វត្តមាននៃសំណើគំរោងរៀបចំស្រេចបាច់ ដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យភាពមានសិទ្ធិទទួលសម្រាប់គំរោង CDM និង/ឬ ការអាក់ខានមិនបានផ្សព្វផ្សាយអំពីកាលានុវត្តភាពគំរោងទាំងនេះ ជូនដល់អ្នកវិនិយោគដែលចាប់អារម្មណ៍
- កំរិតនៃការយល់ដឹងរបស់អ្នកពាក់ព័ន្ធមកពីវិស័យឯកជន ស្តីអំពីកាលានុវត្តភាព CDM នៅក្នុងប្រទេសជាម្ចាស់ផ្ទះដែលមានសក្តានុពលផ្នែក CDM
- កំរិតនៃចំណេះដឹង និងការទទួលយក CDM ដោយភាគីពាក់ព័ន្ធនៅមូលដ្ឋាន ។

ពុំមានវិធីសាស្ត្រ ឬគំរូ “ច្រកចេញចូលតែមួយ” ទេក្នុងការរៀបចំស្ថាប័នជាតិផ្នែក CDM ។ មានលទ្ធភាពច្រើនបែបច្រើនយ៉ាង ហើយប្រទេសនីមួយៗត្រូវតែធ្វើការសម្រេចអំពីទំរង់ដោយឡែកណាមួយនៃការរៀបចំស្ថាប័ន ដែលសមស្រប ហើយដែលអនុលោមតាមស្ថានភាពជាក់ស្តែងរបស់ប្រទេស ។

នៅក្នុងជំពូកនេះ មានបង្ហាញជូនអំពីសេចក្តីសង្ខេបនៃរចនាសម្ព័ន្ធស្ថាប័ន CDM បច្ចុប្បន្នរបស់កម្ពុជា ឡាវ និងវៀតណាម ដោយសង្កត់ធ្ងន់លើ ៖

- លក្ខខណ្ឌដំបូងសម្រាប់ចូលរួមក្នុង CDM ដូចជា ការផ្តល់សច្ចាប័នដល់ពិធីសារក្យូតូ ការជូនដំណឹងស្តីពីការបង្កើត DNA
- ស្ថានភាពនៃបទបញ្ញត្តិពាក់ព័ន្ធនឹង CDM
- ការចូលរួមនៅក្នុង CDM របស់ភាគីពាក់ព័ន្ធក្នុងស្រុក ។

បន្ទាប់មក យើងនឹងធ្វើការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយនៃនីតិវិធីអនុម័តគំរោង ព្រមទាំងមុខងាររបស់ DNA នៅប្រទេសកម្ពុជា និងវៀតណាម ។ យើងក៏នឹងពិនិត្យផងដែរនូវបទពិសោធន៍ក្នុងការអនុវត្ត CDM នៅក្នុងប្រទេសទាំងបី ។

នៅក្នុងជំពូកនេះ ប្រទេសឡាវត្រូវបានផាត់ចេញពីការវិភាគស៊ីជំរៅ ដោយសារតែស្ថាប័ន CDM របស់ប្រទេសនេះស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការបង្កើតនៅឡើយ ។ ពិតមែនតែប្រទេសនេះបានជូនដំណឹងអំពី DNA ទៅលេខាធិការដ្ឋានរបស់ UNFCC ហើយក្តី ក៏មុខងារសំខាន់ៗ និងរចនាសម្ព័ន្ធរបស់ DNA ពុំទាន់ត្រូវបានកំណត់នៅឡើយ ។

## ៤.២ សេចក្តីសង្ខេបអំពីរចនាសម្ព័ន្ធស្ថាប័ន CDM បច្ចុប្បន្ន

### ១. លក្ខខណ្ឌដំបូងសម្រាប់ចូលរួមក្នុង CDM

ប្រទេសកម្ពុជា ឡាវ និងវៀតណាម បានផ្តល់សច្ចាប័នដល់ពិធីសារក្យូតូ នៅឆ្នាំ 2002 ។ ការផ្តល់សច្ចាប័ននេះគឺជាជំហានដំបូងក្នុងការជំរុញគំរោង CDM នៅក្នុងប្រទេសទាំងបីនេះ ។ ក្រោយមក ប្រទេសទាំងបីបានជូនពត៌មានទៅលេខាធិការដ្ឋាន UNFCCC និងពិធីសារក្យូតូ ស្តីពី DNA របស់ខ្លួន ។

### *ក. កម្ពុជា*

កម្ពុជាបានផ្តល់សច្ចាប័នដល់ពិធីសារក្យូតូ នៅខែ សីហា ឆ្នាំ 2002 ហើយបានបង្កើតការិយាល័យប្រែប្រួលអាកាសធាតុ ចំណុះឱ្យក្រសួងបរិស្ថាន នៅខែ មិថុនា ឆ្នាំ 2003 ។ ក្រសួងបរិស្ថានបំពេញនាទីជាស្ថាប័នបណ្តោះអាសន្នទទួលបន្ទុកកិច្ចការយន្តការអភិវឌ្ឍន៍ស្អាត តាមសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល កាលពីខែ កក្កដា ឆ្នាំ 2003 ។ ការិយាល័យប្រែប្រួលអាកាសធាតុបានទទួលថវិកាទាំងស្រុងពីអ្នកផ្តល់ជំនួយបរទេស ហើយរដ្ឋាភិបាលផ្គត់ផ្គង់អាគារ អគ្គិសនី និងទឹក ។

ការងារ CDM របស់ការិយាល័យប្រែប្រួលអាកាសធាតុ ត្រូវបានផ្តល់មូលនិធិ តាមរយៈការចូលរួមនៅក្នុងគំរោង CD4CDM របស់ UNEP-Risoe ។ ការិយាល័យប្រែប្រួលអាកាសធាតុបំពេញការងារប្រកបដោយវិជ្ជាជីវៈខ្ពស់ ហើយមានមន្ត្រីប្រកបដោយភាពស្វាហាប់ ។ ការិយាល័យនេះធ្លាប់បានផ្តល់ការគាំទ្រផ្នែកកសាងសមត្ថភាពដល់ DNA របស់ឡាវដែលមានបុគ្គលិកតែមួយនាក់ ។ ក៏ប៉ុន្តែ គេពុំទាន់ច្បាស់ទេថា តើពេលណាទើបកម្ពុជាធ្វើសេចក្តីសម្រេចចុងក្រោយស្តីពី DNA ។ បច្ចុប្បន្ន កម្ពុជាកំពុងរៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃស្តីពីការអភិវឌ្ឍដោយចីរភាព ។

ដូចក្នុងករណីនៃ DNA បណ្តោះអាសន្នបច្ចុប្បន្នដែរ រចនាសម្ព័ន្ធរបស់ DNA អនាគតដែលស្នើឡើង ផ្តល់នូវតួនាទីចំបងដល់ក្រសួងបរិស្ថាន ។ ដំណើរការអនុម័តគំរោង CDM ដែលស្នើឡើង មានភាពស្រដៀងគ្នា ។ ក៏ប៉ុន្តែ រចនាសម្ព័ន្ធថ្មីនេះត្រូវបានរៀបចំឡើង ដោយផ្តល់ជូនអ្នកដើរតួក្នុង DNA សំខាន់ៗ នូវមុខនាទីជាក់លាក់ នៅក្នុងដំណើរការវាយតម្លៃ ។

*ខ. ឡាវ*

កាលពីចុងឆ្នាំ 2004 ឡាវបានជូនដំណឹងថា ទីភ្នាក់ងារផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន នៅក្នុងការិយាល័យនាយករដ្ឋមន្ត្រី គឺជា DNA ។ ក៏ប៉ុន្តែ សិក្ខាសាលាថ្មីៗនេះនៅប្រទេសឡាវបានបង្ហាញថា សេចក្តីសម្រេចនេះត្រូវបានធ្វើឡើង ដោយគេស្មានថា DNA គ្រាន់តែជាឈ្មោះផ្សេងមួយទៀតរបស់ជនបង្គោលផ្នែកប្រែប្រួលអាកាសធាតុ ហើយថា សមត្ថកិច្ចធ្វើសេចក្តីសម្រេចពុំជាប់ទាក់ទងនឹងមុខងាររបស់ DNA ទេ ។ បច្ចុប្បន្ន គេបានឯកភាពគ្នាថា នឹងធ្វើសំណើមួយដើម្បីដាក់ធ្វើ DNA ជាមួយនឹងគណៈកម្មាធិការដែលមានស្រាប់ណាមួយ ហើយត្រូវតែរៀបចំនូវនីតិវិធីច្បាស់លាស់ ។ បញ្ហាពិបាកចំបងគឺអវត្តមាននៃសំណើគំរោង ដែលរារាំងមន្ត្រី DNA មិនឱ្យទទួលបាននូវបទពិសោធន៍ ។ មុខងារសំខាន់ៗរបស់ DNA ឡាវ កំពុងស្ថិតនៅក្នុងការពិភាក្សានៅឡើយ ។

បើធៀបជាមួយនឹងកម្ពុជា និងវៀតណាម ក្នុងផ្នែកដំណើរការ DNA និងកសាងក្របខ័ណ្ឌជាតិ ប្រទេសឡាវស្ថិតនៅឆ្ងាយខាងក្រោយ ជាមួយនឹងផលវិបាកធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងភាពគ្មានការទាក់ទាញ នៅក្នុងទីផ្សារកាបូនជារួម និងនៅក្នុងការរកអ្នកផ្តល់ជំនួយហិរញ្ញវត្ថុជាពិសេស ។

*គ. វៀតណាម*

វៀតណាមគឺជាប្រទេសដំបូងគេមួយនៅអាស៊ី ដែលបានបង្កើត DNA របស់ខ្លួន ។ ឯកសារផ្លូវការលេខ 502/BTNMT-HTQT ចុះថ្ងៃទី 24 ខែមីនា ឆ្នាំ 2003 បានចែងថា នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងបរិស្ថាន និងធនធានធម្មជាតិ (Ministry of Natural Resources and the Environment: MONRE) បំពេញនាទីជា DNA ។ សេចក្តីសម្រេចលេខ 553/QC-BTNMT ចុះថ្ងៃទី 29 ខែមេសា ឆ្នាំ 2003 កំណត់នូវក្រុមប្រឹក្សាពិគ្រោះយោបល់ និងប្រតិបត្តិ CDM (CDM National Executive and Consultative Board: CNECB) ដែលមានតំណាងមកពីក្រសួងដូចទៅនេះ ៖ MONRE (មានសមាជិកបីនាក់), ក្រសួងពាណិជ្ជកម្ម, ក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, ក្រសួងការបរទេស, ក្រសួងហិរញ្ញវត្ថុ, ក្រសួងផែនការ និងវិនិយោគ, ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ, ក្រសួងឧស្សាហកម្ម, និងសហជីពនៃបណ្តាសមាគមវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាវៀតណាម ដែលជាអង្គការមិនមែនរដ្ឋាភិបាលរបស់រដ្ឋាភិបាល ។

CNECB ជួបប្រជុំពីរដងក្នុងមួយឆ្នាំ (ខែមេសា និងកញ្ញា) ។ ដោយយល់ឃើញថា ការប្រជុំកន្លះឆ្នាំម្តងរបស់ CNECB នឹងបណ្តាលឱ្យមានភាពពុំអាចបត់បែនបាន និងពុំសូវមានប្រសិទ្ធភាពខាងពេលវេលាសម្រាប់អ្នកអភិវឌ្ឍគំរោង គេបានសម្រេចជួបប្រជុំ CNECB ឱ្យបានញឹកញាប់ ចាប់ពីរដូវស្លឹកឈើជ្រុះ ឆ្នាំ 2005 តទៅ ។

លក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍដោយចីរភាពមួយឈុតដំបូងត្រូវបានរៀបចំឡើង ក៏ប៉ុន្តែមន្ត្រីរបស់ MONRE នៅពុំទាន់បានយកទៅប្រើប្រាស់នៅឡើយ ។ កិច្ចប្រជុំនៅរដូវផ្ការីកឆ្នាំ 2004 បានពិភាក្សាអំពីលក្ខណៈវិនិច្ឆ័យសម្រាប់គំរោងថាមពល បន្ទាប់មកកិច្ចប្រជុំនៅរដូវស្លឹកឈើជ្រុះឆ្នាំដដែល បានពិភាក្សាអំពីក្របខ័ណ្ឌច្បាប់ទូទៅ ។ នៅក្រោមជំនួយរបស់ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) គេបានកែសំរួលលក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍដោយចីរភាព ឱ្យទៅជាស្តង់ដារបរិមាណ ។ ឯកសារគំរោង (PDDs) ជាភាសាវៀតណាម និងអង់គ្លេស ជាមួយនឹងលិខិតអនុញ្ញាតពីក្រសួង

ពាក់ព័ន្ធ ត្រូវដាក់ជូនពិនិត្យឱ្យបានមួយខែ មុនកិច្ចប្រជុំរបស់ CNECB ។ បណ្តាក្រសួងដែលមានកៅអីនៅក្នុង DNA នឹងផ្តល់យោបល់ទៅសមាជិក CNECB របស់ខ្លួន ។ បន្ទាប់មក CNECB ធ្វើការសម្រេចតាមរយៈការបោះឆ្នោត ដោយសម្លេងភាគច្រើនបីភាគបួន ។ គំរោងដែលបដិសេធ អាចយកមកដាក់ជូនឱ្យពិនិត្យជាថ្មីច្រើនដងទៀត ។ ឯកសារជាភាសាវៀតណាមស្តីអំពីវដ្តគំរោង នឹងត្រូវចេញផ្សាយក្នុងពេលឆាប់ៗខាងមុខ ។

## ២. ស្ថានភាពនៃបទបញ្ញត្តិពាក់ព័ន្ធនឹង CDM

ការពិនិត្យឡើងវិញនូវបទបញ្ញត្តិរបស់ជាតិមានសារៈសំខាន់ ពីព្រោះថាក្របខ័ណ្ឌច្បាប់របស់ប្រទេសជាម្ចាស់ផ្ទះណាមួយនឹងមានឥទ្ធិពលផ្ទាល់ទៅលើជោគជ័យនៃ DNA ។ អាស្រ័យលើអាទិភាពអភិវឌ្ឍន៍របស់ប្រទេសជាមាស់ផ្ទះ បទបញ្ញត្តិដែលមានស្រាប់ខ្លះអាចយកមកប្រើការសម្រាប់ CDM បាន ។ ដូចក្នុងករណីពាណិជ្ជកម្ម និងវិនិយោគទូទៅដែរ ប្រទេសម្ចាស់ផ្ទះដែលមាននីតិវិធានប្រកបដោយតម្លាភាព និងបែបបទរលូន នឹងមានជំហរល្អប្រសើរក្នុងការប្រកួតប្រជែងយកធនធាន CDM ។

យុទ្ធសាស្ត្រជាតិផ្នែក CDM ត្រូវតែផ្អែកលើគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ប្រទេស ។ ជាប្រការសំខាន់ដែលគេត្រូវកំណត់នូវគោលនយោបាយជាតិ ដែលបានបង្កើតរួចហើយ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម នៅក្នុងវិស័យដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដូចជា ថាមពល ការប្រើប្រាស់ដី ការប្រែប្រួលក្នុងការប្រើប្រាស់ដីនិងព្រៃឈើ ឧស្សាហកម្ម ។ល។ គោលនយោបាយទាំងនេះនឹងមានផលប៉ះពាល់លើធនធានធម្មជាតិ និងបរិស្ថាន នៅថ្នាក់មូលដ្ឋាន ព្រមទាំងលើការប្រែប្រួលអាកាសធាតុ នៅកំរិតពិភពលោក ។ CDM គឺជាកាលានុវត្តភាពយ៉ាងពិតប្រាកដ ក្នុងការស្រូបយកធនធានសម្រាប់គំរោងនានា ដែលអាចគាំទ្រដល់បណ្តាអាទិភាពអភិវឌ្ឍន៍របស់ជាតិ ។

ការវិនិយោគ CDM នៅកម្ពុជា និងវៀតណាម ត្រូវបានធ្វើនិយ័តកម្ម ភាគច្រើនដោយផ្អែកលើច្បាប់ និងបទបញ្ញត្តិដែលមានស្រាប់ ដែលត្រូវបានយកទៅអនុវត្តសម្រាប់គ្រប់គ្រងសកម្មភាពវិនិយោគធម្មតា ។ នៅប្រទេសឡាវពុំទាន់ មានបញ្ជីបទបញ្ញត្តិដែលមានស្រាប់ ដែលអាចដឹកនាំសកម្មភាពវិនិយោគ CDM នៅឡើយ ។

### *ក. ដំណើរការអនុម័តគំរោងCDM នៅកម្ពុជា*

ក្របខ័ណ្ឌច្បាប់ បណ្តាច្បាប់ ព្រមទាំងបទបញ្ញត្តិសម្រាប់ការវិនិយោគ CDM នៅប្រទេសកម្ពុជា មានបង្ហាញជូននៅក្នុងរូបទី ៨ ។




*រូបទី ៨. រូបបំព្រួញបង្ហាញពីបទបញ្ញត្តិសំខាន់ដែលពាក់ព័ន្ធនឹងគំរោង CDM នៅកម្ពុជា*

នីតិវិធីអនុម័តគំរោង CDM ដែលស្នើឡើងមានបង្ហាញជូននៅក្នុងរូបទី ៩ ។ រយៈពេលនៃដំណើរការវាយតម្លៃមានចំនួន 55 ថ្ងៃ ។




*រូបទី ៩. ដំណើរការអនុម័តគំរោង CDM ដែលស្នើឡើងនៅកម្ពុជា*

### *ខ. ដំណើរការអនុម័តគំរោង CDM នៅវៀតណាម*

បច្ចុប្បន្ន វៀតណាមកំពុងតែរៀបចំគោលការណ៍ណែនាំមួយរបស់នាយករដ្ឋមន្ត្រី ស្តីពី CDM ដើម្បីជំរុញគំរោង CDM ។ គេមានគំរោងឱ្យគោលការណ៍ណែនាំនេះចូលជាធរមាន នៅចុងឆ្នាំ 2005 ។ មានច្បាប់ និង/ឬ បទបញ្ញត្តិមួយចំនួន ដែលគំរោងវិនិយោគទាំងអស់នៅវៀតណាមត្រូវតែអនុវត្តតាម ដោយរួមទាំងគំរោង CDM ផង ដូចជា ៖

- ច្បាប់ស្តីពីការវិនិយោគបរទេសផ្ទាល់ ក្រសួងផែនការ និងវិនិយោគ
- ច្បាប់ស្តីកិច្ចការពារបរិស្ថាន ក្រសួងធនធានធម្មជាតិ និងបរិស្ថាន
- ច្បាប់ស្តីពីហិរញ្ញវត្ថុ ក្រសួងហិរញ្ញវត្ថុ
- ច្បាប់ស្តីពីពន្ធដារ ក្រសួងហិរញ្ញវត្ថុ ។

ក្រៅពីច្បាប់ទាំងនេះ មានច្បាប់ និង/ឬបទបញ្ញត្តិដោយឡែកតាមវិស័យនានា ដែលគំរោង CDM តាមបណ្ដាវិស័យទាំងនោះ ត្រូវអនុវត្តតាម ដូចជាគំរោង CDM ក្នុងវិស័យដាំព្រៃឈើ និងស្ដារព្រៃឈើ គំរោង CDM ក្នុងវិស័យថាមពលជាដើម ។ នៅក្នុងវិស័យថាមពល បទបញ្ញត្តិតាមវិស័យដែលពាក់ព័ន្ធរួមមាន ៖

- ក្រឹត្យរបស់រដ្ឋាភិបាលលេខ 45/2001/ND-CP ចុះថ្ងៃទី 2 ខែសីហា ឆ្នាំ 2001 ស្ដីអំពីសកម្មភាព និងការប្រើប្រាស់អគ្គិសនី
- ច្បាប់ស្ដីពីធនធានរ៉ែ
- ច្បាប់ស្ដីពីប្រេងកាត និងឧស្ម័ន
- គោលនយោបាយជាតិស្ដីអំពីថាមពល ។

ប្រសិនបើមានគំរោង CDM ណាមួយត្រូវបានធ្វើឡើង នៅក្នុងវិស័យកសិកម្ម នោះគំរោងនេះត្រូវតែអនុលោមទៅតាម "យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកសិកម្ម និងរុក្ខកម្ម ដល់ឆ្នាំ 2020" ។ "ច្បាប់ស្ដីពីកិច្ចការពារ និងការអភិវឌ្ឍព្រៃឈើ" នឹងត្រូវយកមកអនុវត្តសម្រាប់គំរោង CDM ព្រៃឈើ ។ បទបញ្ញត្តិសំខាន់ៗ ដែលពាក់ព័ន្ធនឹងគំរោង CDM នៅប្រទេសវៀតណាម មានសង្ខេបជូនក្នុងតារាងទី ១០ ។




*រូបទី ១០. បទបញ្ញត្តិដែលពាក់ព័ន្ធនឹងគំរោង CDM នៅប្រទេសវៀតណាម*

នីតិវិធីអនុម័តគំរោង CDM ដែលស្នើឡើង មានបង្ហាញជូននៅក្នុងរូបទី ១១ ។




*រូបទី ១១. ដំណើរការអនុម័តគំរោង CDM ដែលស្នើឡើងនៅវៀតណាម*

## ៣. ស្ថានភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងស្រុកនៅក្នុង CDM

ការសម្រេចបាននូវការចូលរួមយ៉ាងទូលំទូលាយពីភាគីពាក់ព័ន្ធ គឺជាចំណោទដ៏លំបាកមួយសម្រាប់ប្រទេសជាម្ចាស់ផ្ទះ ដើម្បីជំរុញគំរោង CDM ។ ប្រទេសខ្លះមានកម្មវិធីបែបមជ្ឈការនៅក្នុងក្របខ័ណ្ឌស្ថាប័នរបស់រដ្ឋាភិបាលកណ្តាល ។ ប្រទេសខ្លះទៀតបានធ្វើឱ្យសម្រេចនូវការចូលរួមយ៉ាងសកម្មពីបណ្តាភាគីពាក់ព័ន្ធទាំងអស់នៅក្នុងសង្គម និងនៅក្នុងវិស័យផ្សេងៗនៃសេដ្ឋកិច្ច ។ ការដាក់ឱ្យមានការចូលរួមរបស់វិស័យឯកជន អាចលើកទឹកចិត្តឱ្យមានវិធីសាស្ត្រដែលមានភាពការិយាធិបតេយ្យតិច ផ្តោតលើលទ្ធផលច្រើន និងតាមបែបជំនួញ ។ អ្នកអភិវឌ្ឍន៍ឯកជន និងសាធារណៈ រួមគ្នា ឬដោយឡែកពីគ្នា គឺជាអ្នកដើរតួយ៉ាងពិតប្រាកដ និងជាកម្លាំងចលករ សម្រាប់ការអនុវត្តបណ្តាជំរើសកាត់បន្ថយឧស្ម័នដែលចំណាយតិច (Manso, 2003) ។

ដោយសារតែវត្តមានតិចតួចនៃអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាសហគមន៍ឯកជន នៅក្នុងសកម្មភាពសេដ្ឋកិច្ច-សង្គម របស់ប្រទេសទាំងបី គេប្រហែលជាពិបាករំពឹងថា នឹងមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់អ្នកដើរតួទាំងនេះណាស់ ។

តាមការពិសោធន៍របស់កម្ពុជា និងវៀតណាម អាទិភាពចំបងគឺការសម្រេចបាននូវកិច្ចសហប្រតិបត្តិការរលូន និងប្រកបដោយការគាំទ្រ រវាងបណ្តាក្រសួង និងភ្នាក់ងាររបស់រដ្ឋាភិបាល ចាប់តាំងពីពេលចាប់ផ្តើមបង្កើតរចនាសម្ព័ន្ធនៃស្ថាប័ន CDM របស់ជាតិ ។ ក៏ប៉ុន្តែ កត្តានេះគ្រាន់តែជាលក្ខខណ្ឌចាំបាច់ តែមិនគ្រប់គ្រាន់ទេ ក្នុងការបង្កើតនូវកម្លាំងចលករសម្រាប់ជំរុញសកម្មភាព CDM ។

នៅក្នុងប្រទេសទាំងពីរនេះ មកទល់បច្ចុប្បន្ន គេបានសម្រេចនូវអាទិភាពទីមួយក្នុងក្នុងការបង្កើតនូវកិច្ចសហប្រតិ-បត្តិការអន្តរក្រសួងដោយរលូន តាមរយៈបណ្តាគំរោងពង្រឹងសមត្ថភាពស្ថាប័ន ។ អាស្រ័យហេតុនេះ អាទិភាពនៃបណ្តាកម្មវិធីកសាងសមត្ថភាពសម្រាប់ដំណាក់កាលបន្ទាប់ គឺការកសាងសមត្ថភាពរបស់អ្នកដើរតួក្នុងស្រុក ដើម្បីលើកស្ទួយ

តម្រូវការមុខជំនួញសម្រាប់ការចូលរួមក្នុង CDM ពីស្ថានភាពដើម ។ អ្នកពាក់ព័ន្ធដែលត្រូវចូលរួមគួរតែជាបណ្តាក្រុមហ៊ុន អ្នកផ្តល់យោបល់ដែលមានជំនាញខាងថាមពលនិងបញ្ហាបរិស្ថាន ព្រមទាំងធនាគារ និងបណ្តាស្ថាប័នហិរញ្ញវត្ថុនានា ។

*តារាងទី ៧. អ្នកពាក់ព័ន្ធក្នុងស្រុកដែលចូលរួមក្នុងគំរោង CDM និងមុខងារចំបងរបស់ពួកគេ*

| | |
|---|---|
| រដ្ឋាភិបាល | • ការសម្របសម្រួលទូទៅ និងសេវាកម្មពតិមាន<br>• រៀបចំ និងផ្តល់ការគាំទ្រដល់ការកសាងសមត្ថភាព/ជំនាញពាក់ព័ន្ធនឹង CDM នៅគ្រប់ថ្នាក់<br>• រៀបចំគោលនយោបាយឧស្ម័នផ្ទះកញ្ចក់ ដោយរួមទាំងការដាក់បញ្ចូលនូវគោលនយោបាយទាំងនេះទៅក្នុងគោលនយោបាយតាមវិស័យនានា<br>• រៀបចំបណ្តាវិធានដោយឡែក និងលក្ខណៈវិនិច្ឆ័យសម្រាប់ CDM<br>• កំណត់នូវស្តង់ដារ/ពិធីសារ<br>• ការគ្រប់គ្រងវដ្តគំរោង (ការវាយតម្លៃ ការជ្រើសរើស)<br>• ការធ្វើសហហិរញ្ញប្បទានគំរោង ដូចជាតាមរយៈប្រាក់ចំណូលពីពន្ធ $CO_2$<br>• ផ្ទៀងផ្ទាត់ (រួមទាំង លក្ខខណ្ឌគោល ភាពបន្ថែម ការអង្កេតតាមដាន)<br>• ការអនុវត្តច្បាប់<br>• ការធ្វើរបាយការណ៍ទៅ UNFCCC |
| សហគ្រាស, ឧស្សាហកម្ម | • រៀបផែនការ និងស្នើគំរោង<br>• ផ្តល់ហិរញ្ញប្បទានដល់គំរោង<br>• អនុវត្តគំរោង<br>• អង្កេតតាមដានការបញ្ចេញឧស្ម័ន និងលក្ខខណ្ឌគោល<br>• ធ្វើរបាយការណ៍ស្តីពីគំរោងដែលទទួលជោគជ័យ និងបញ្ហានានា<br>• ផ្តល់មតិយោបល់ស្តីពីប្រសិទ្ធភាពនៃនីតិវិធី ។ល។ |
| ស្ថាប័ន, ក្រុមហ៊ុនដែលផ្តល់ជំនាញពិសេស | • ផ្តល់ចំណេះដឹងផ្នែកបច្ចេកទេស សេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• ជួយកៀរគរវិស័យឧស្សាហកម្ម<br>• គណនាលក្ខខណ្ឌគោល<br>• ការធ្វើម៉ូដែល<br>• សេវាកម្មផ្ទៀងផ្ទាត់ និងផ្តល់វិញ្ញាបនប័ត្រ |
| អង្គការមិនមែនរដ្ឋាភិបាល | • ជួយលើកកំពស់ការយល់ដឹងជាសាធារណៈស្តីពី CDM<br>• ជួយកំណត់គំរោង<br>• តួនាទីជាអ្នកឃ្លាំមើលផ្នែកគោលនយោបាយ នីតិវិធី ការអនុវត្តគំរោង ការអនុវត្តច្បាប់ |

## ៤.៣ ការវាយតម្លៃស្ថាប័ន CDM របស់ជាតិ

ក្រៅពីការមានស្ថាប័ន CDM ជាតិសមស្របមួយ នីតិវិធីនៃការអនុម័តគំរោងមានសារៈសំខាន់បំផុតសម្រាប់អ្នកវិនិយោគ ដោយហេតុថា ជំហាននេះជាអ្នកកំណត់នូវការចំណាយមួយផ្នែកដែលនឹងកើតមាន ។

ដោយផ្អែកលើការរៀបចំនីតិវិធីអនុម័តគំរោង CDM នៅកម្ពុជា និងវៀតណាម យើងបានធ្វើការវិភាគភាពខ្លាំង និងភាពខ្សោយរបស់នីតិវិធីទាំងនេះ សម្រាប់ប្រទេសនីមួយៗ ។ សេចក្តីលំអិតអំពីលក្ខណៈវិនិច្ឆ័យ និងលទ្ធផល មានបង្ហាញនៅក្នុងតារាងទី ៨ ឯតារាងទី ៩ បង្ហាញពីការវាយតម្លៃលើមុខងាររបស់ DNA នៅកម្ពុជា និងវៀតណាម ។

*តារាងទី ៨. ការវាយតម្លៃលើភាពខ្លាំង (S) និងភាពខ្សោយ (W) របស់នីតិវិធីអនុម័តគំរោង CDM នៅកម្ពុជា និងវៀតណាម*

| លក្ខណៈវិនិច្ឆ័យ | កម្ពុជា | វៀតណាម |
|---|---|---|
| ប្រសិទ្ធភាពចំណាយ | S: ពុំមានការចំណាយសម្រាប់ការអនុម័ត | S: ពុំមានការចំណាយសម្រាប់ការអនុម័ត |
| ប្រសិទ្ធភាពពេលវេលា | 55 ថ្ងៃធ្វើការសម្រាប់ការអនុម័តគំរោង CDM<br>S: បង្ហាញរយៈពេលច្បាស់លាស់សម្រាប់អនុម័តគំរោង, ច្រកចេញចូលតែមួយ<br>W: រយៈពេលមធ្យមបើធៀបជាមួយនឹង DNAs ផ្សេងទៀត | ត្រូវដាក់ជូនពិនិត្យឱ្យបាន 1 ខែ មុនកិច្ចប្រជុំរបស់ CNECB នៅខែមេសា ឬខែកញ្ញា<br>W: មានប្រសិទ្ធភាព និងភាពបត់បែនតិច បើធៀបជាមួយនឹងប្រទេសផ្សេងទៀត និងពេលវេលា ក្នុងដំណាក់កាលអន្តរជាតិ |
| ការកំណត់បណ្តាខដែលត្រូវធ្វើ ( ការវាយតម្លៃហេតុបះពាល់បរិស្ថាន, ការអនុលោមតាមក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ, ផែនការអភិវឌ្ឍន៍ជាតិ ឬតាមវិស័យ) | S: ផ្តល់នូវបទបញ្ញត្តិដែលត្រូវអនុវត្តសម្រាប់គំរោង CDM | S: ផ្តល់នូវបទបញ្ញត្តិដែលត្រូវអនុវត្តសម្រាប់គំរោង CDM<br>W: ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គំរោងទាំងអស់ |
| សំណុំលក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍដោយចិរភាពដែលមានសង្គតភាព | W: លក្ខណវិនិច្ឆ័យមានភាពទូទៅ និងបែបបរិមាណ | W: លក្ខណវិនិច្ឆ័យមានភាពទូទៅខ្លាំងពេក និងបែបបរិមាណ |
| ការផ្តល់នូវការអង្កេតតាមដាន និងការវាយតម្លៃមុន-ក្រោយ | W: ពុំទាន់មាន | W: ពុំទាន់មាន |
| ឯកសារគំរោងដែលតម្រូវ | S: ដាក់ជូនពិនិត្យតែ PDD | តម្រូវឱ្យដាក់ទូនពិនិត្យ ទាំង PDD ទាំង PIN<br>S: មានហានិភ័យអប្បបរមា<br>W: បង្កើនបន្ទុកដល់អ្នកអភិវឌ្ឍគំរោង |
| នីតិវិធីងាយសម្រាប់គំរោងខ្នាតតូច | W: ពុំទាន់មាន | W: ពុំទាន់មាន |

*តារាងទី ៩. ការវាយតម្លៃមុខងារ របស់កម្ពុជា DNA និងវៀតណាម*

| លក្ខណៈវិនិច្ឆ័យ | កម្ពុជា | វៀតណាម |
|---|---|---|
| **មុខងារណែនាំ** | | |
| កញ្ចប់គំរោងអាទិភាព | x | x |
| ការសិក្សាយុទ្ធសាស្ត្រ | x | x |
| ការរៀបចំគោលនយោបាយ | x | x |
| **មុខងារនិយ័តកម្ម** | | |
| ការវាយតម្លៃ និងអនុម័តគំរោង | x | x |
| ការចុះបញ្ជីថ្នាក់ជាតិ និងការធ្វើរបាយការណ៍គំរោង | -- | -- |
| **មុខងារផ្សព្វផ្សាយ** | | |
| ការលើកកំពស់ការយល់ដឹង ៖ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ/ការផ្តល់ពត៌មាន | x | x |
| ជំនួយបច្ចេកទេស និងពាណិជ្ជកម្ម | -- | -- |
| **ការសម្របសម្រួលជាមួយក្រសួងនានា** | ល្អបង្គួរ | ល្អ |
| **ការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ** | ការចូលរួមមានកំរិតពីវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល | ការចូលរួមមានកំរិតពីវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល |

សរុបសេចក្តីទៅ ប្រព័ន្ធស្ថាប័ន CDM នៅកម្ពុជា និងវៀតណាម ត្រូវបានគេរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌចាំបាច់នានា ដើម្បីចូលរួមក្នុងទីផ្សារកាបូន ។ ក៏ប៉ុន្តែ ការធ្វើឱ្យប្រព័ន្ធនេះលេចធ្លោឡើង នៅក្នុងទីផ្សារ CDM ពាក់ព័ន្ធនឹងភាពប្រកួតប្រជែងផ្នែកស្ថាប័ន CDM នឹងអាស្រ័យលើប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ប្រព័ន្ធទាំងពីរនេះ ។

## ៤.៤ បទពិសោធន៍ផ្នែកគំរោងប្រែប្រួលអាកាសធាតុ

ពិតមែនតែការសិក្សារបស់អ្នកឯកទេស Point Carbon បានបង្ហាញថា បទពិសោធន៍នៅក្នុងការរៀបចំ និងការអនុវត្តគំរោងការប្រែប្រួលអាកាសធាតុរបស់ប្រទេសជាម្ចាស់ផ្ទះ គឺគ្រាន់តែជាកត្តាសំខាន់តិចតួច ក្នុងចំណោមអថេរទាំងបីដែលកំណត់នូវភាពទាក់ទាញរបស់ប្រទេសផ្នែក CDM ក្តី ក៏ការអះអាងនេះអាចពិតតែសម្រាប់ទីផ្សារ CDM បច្ចុប្បន្នដែលនៅក្មេងខ្ចី ប៉ុណ្ណោះ ។ នៅក្នុងរយៈពេលវែង បទពិសោធន៍សំបូរបែបមិនមែនមានន័យថាគ្រាន់តែជាបរិមាណច្រើននៃបណ្តាគំរោង CDM ដែលមានសក្តានុពលអាចអនុវត្តបានប៉ុណ្ណោះទេ ក៏ប៉ុន្តែគេចាំបាច់ត្រូវមានស្ថាប័ន CDM ដែលដំណើរការប្រកបដោយប្រសិទ្ធភាព និងបរិស្ថានវិនិយោគល្អ នៅក្នុងប្រទេសជាម្ចាស់ផ្ទះ ។

មកទល់បច្ចុប្បន្ន មានតែប្រទេសវៀតណាមទេ ដែលបានអនុវត្តគំរោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ពីរ ក្នុងដំណាក់កាលសាកល្បងរបស់ AIJ (សូមមើលតារាងទី ១០ សម្រាប់ពត៌មានលំអិត) ។

*តារាងទី ១០. គំរោងAIJ របស់វៀតណាម ដែលបានចុះបញ្ជីហើយនៅលេខាធិការដ្ឋាន UNFCCC*

| ឈ្មោះគំរោង | អ្នកវិនិយោគ | ប្រភេទគំរោង | ថវិកាគំរោង | ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (គិតជាតោនសមមូល $CO_2$) |
|---|---|---|---|---|
| ការបង្កើនការស្រូបយកកាបូនតាមរយៈការប្រើប្រាស់ស្តុករុក្ខជាតិដែលបានកែលំអសេនេទិច | CSIRO Forestry and Forest Products, អូស្ត្រាលី | ការដាំព្រៃឈើ | US$242.000 | ស្រូបយកកាបូន 5.900 តោន (21.500 $CO_2$) ក្នុងមួយឆ្នាំ |
| គំរោងគំរូដើម្បីកាត់បន្ថយការប្រើប្រាស់អគ្គិសនីនៅរោងចក្រស៊ីម៉ងត៍ហាទៀងទី 2 | អង្គការអភិវឌ្ឍន៍បច្ចេក-វិទ្យា និងថាមពលថ្មីរបស់ប្រទេសជប៉ុន (NEDO) | ប្រសិទ្ធភាពថាមពល | គ្មានពតិមាន | 14.230 តោន ក្នុងមួយឆ្នាំ |

*ប្រភព ៖ លេខាធិការដ្ឋាន UNFCCC*

មកទល់ខែកញ្ញា ឆ្នាំ 2005 PDD ចំនួនបីពីវៀតណាម និងមួយពីកម្ពុជា ត្រូវបានដាក់ជូនទៅ UNFCCC ដើម្បីផ្តល់សុពលភាព (បើលតារាងទី ១១ សម្រាប់ពតិមានលំអិត) ។

ជាទូទៅ បទពិសោធន៍របស់ប្រទេសទាំងបីនេះនៅក្នុងការរៀបចំគំរោង CDM ជាពិសេសអវត្តមាននៃបទពិសោធន៍របស់ប្រទេសឡាវ មានភាពស៊ីគ្នាទៅនឹងភាពអំណោយផលផ្នែក CDM និងកំរិតនៃសមត្ថភាពស្ថាប័នរបស់ប្រទេសនីមួយៗ ។

ប្រទេសកម្ពុជា និងវៀតណាមបានបង្កើតនូវ DNA របស់ខ្លួន និងស្ថាប័នសំខាន់ៗផ្សេងទៀត ដើម្បីសំរួលដល់ការអភិវឌ្ឍគំរោង CDM នៅក្នុងប្រទេសរបស់ខ្លួន ។ ក៏ប៉ុន្តែ អវត្តមាននៃលក្ខណៈវិនិច្ឆ័យបែបបរិមាណដោយឡែកសម្រាប់វាយតម្លៃគំរោង CDM នៅក្នុងប្រទេសទាំងពីរ អាចនាំឱ្យមានការធ្វើសេចក្តីសម្រេចដោយផ្អែកលើគំរោងមួយៗ ហើយអាចនាំឱ្យដំណើរការអនុម័តគំរោងពុំសូវមានតម្លាភាព ។ បើនិយាយពីមុខងាររបស់ DNA វិញ យើងឃើញថា មុខងារផ្សព្វផ្សាយហាក់បីដូចជាពុំត្រូវបានយកមកពិចារណាឱ្យសមស្រប ។ ជាផលវិបាក ការយល់ដឹងអំពីសក្តានុពលរបស់ប្រទេស ក៏ដូចជាភាពប្រកួតប្រជែងរបស់ប្រទេស ពុំត្រូវបានជ្រួតជ្រាបឱ្យបានសមល្មម នៅទីផ្សារ CDM ហើយប្រការនេះបានដាក់កំរិតដល់កាលានុវត្តភាពក្នុងការទាក់ទាញអ្នកវិនិយោគ អ្នកទិញ និងអ្នកផ្តល់ជំនួយ ។

ស្ថាប័ន CDM នៅប្រទេសឡាវកំពុងស្ថិតនៅក្រោមការរៀបចំនៅឡើយ ។ ប្រការល្អមួយគឺថា ប្រទេសនេះអាចរៀនសូត្រពីកម្ពុជា និងវៀតណាម ដើម្បីរៀបចំ DNA របស់ខ្លួនមួយ ដែលមានប្រសិទ្ធភាព និងប្រកបដោយភាពបត់បែន ។ ក៏ប៉ុន្តែ ប្រសិនបើដំណើរការរៀបចំនេះមិនប្រព្រឹត្តទៅឱ្យបានលឿនសមល្មម ដើម្បីឱ្យទាន់បណ្តាប្រទេសជិតខាងទេ នោះឱកាសចូលទៅក្នុងទីផ្សារ CDM នឹងកាន់តែតូចចង្អៀត ជាពិសេសនៅពេលដែលសក្តានុពល CDM នៅឡាវមានតិចតួច ។

*តារាងទី ១១. PDDs ដែលបានដាក់ជូនសុំការផ្ដល់សុពលភាព*

| ប្រទេស | ឈ្មោះគំរោង | អ្នកវិនិយោគ | ប្រភេទគំរោង | ថវិកាគំរោង (លាន US$) | ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (គិតជាតោនសមមូល $CO_2$) ត្រឹមឆ្នាំ 2012 |
|---|---|---|---|---|---|
| កម្ពុជា | គំរោងថាមពលអង្គរ Bio Cogen | • Mitsubishi Securities<br>• Angkor Bio Cogen | ថាមពលកកើតឡើងវិញ | 3,5 | 240,000 |
| វៀតណាម | គំរោងចាប់យក និងប្រើប្រាស់ឧស្ម័នពីអណ្តូងប្រេង នៅ Baria ខេត្តវុងតាវ | • PetroVietnam<br>• Japan Vietnam Petroleum<br>• PVEP<br>• Conocophillips Gama | ការចាប់យកឧស្ម័ន | 73 | 6770 |
| វៀតណាម | គំរោងគំរូសម្រាប់ការកែលំអដើម្បីបង្កើនប្រសិទ្ធភាពប្រើប្រាស់ថាមពលនៅរោងចក្រស្រាបៀរ ខេត្តថាញ់ហោ | • HABECO<br>• Thanh Hoa Beer Joint Stock Company<br>• NEDO, Mayekawa MFG | ប្រសិទ្ធភាពថាមពល | 3,64 | 71 |
| វៀតណាម | គំរោងប្រព្រឹត្តកម្មសំណល់រាវដោយគ្មានខ្យល់ និងការចាប់យកថាមពលនៅក្រុមហ៊ុនផលិតជ័រកៅស៊ូនៅវៀតណាម | • Nippon Mining Research<br>• Vietnam Rubber Corp<br>• Baria Ruber Corp | ការចាប់យកមេតានពីអណ្តូងរ៉ែ | គ្មានពតិមាន | 51 |

*ប្រភព ៖ គេហទំព័ររបស់ UNFCCC គិតត្រឹមថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៥*

# ៥. សេចក្តីសន្និដ្ឋាន

## ៥.១ ចំណាត់ថ្នាក់ភាពប្រកួតប្រជែងផ្នែក CDM របស់ប្រទេស

ដើម្បីបង្ហាញឱ្យឃើញជាបរិមាណនូវភាពប្រកួតប្រជែងរបស់ប្រទេសទាំងបី នៅក្នុងទីផ្សារ CDM ពិភពលោក យើងបានចាត់ថ្នាក់ប្រទេសទាំងបី ដោយផ្អែកលើអថេរបី ដែលកំណត់នូវភាពប្រកួតប្រជែងរបស់ប្រទេស ហើយដែលត្រូវបានធ្វើការវិភាគ និងវាយតម្លៃ នៅក្នុងជំពូកមុនៗ (តារាងទី ១២) ។

*តារាងទី ១២. ចំណាត់ថ្នាក់ភាពប្រកួតប្រជែង CDM របស់ប្រទេស*

| ប្រទេស | សរុប | សមត្ថភាព CDM | ស្ថាប័ន CDM និងបទ-ពិសោធន៍គំរោង CDM | បរិស្ថានវិនិយោគ |
|---|---|---|---|---|
| វៀតណាម | B | B | B+ | CCC |
| កម្ពុជា | CC | C | B | C+ |
| ឡាវ | C- /D | C | C- | C- |

មាត្រដ្ឋានសម្រាប់ចំណាត់ថ្នាក់នៅក្នុងការសិក្សានេះ ត្រូវបានបង្កើតឡើង ដោយផ្អែកលើ Point Carbon ប៉ុន្តែវាអាចមិនត្រូវគ្នាជាមួយនឹងការចាត់ថ្នាក់របស់ Point Carbon ដោយសារថា ក្រុមមាត្រដ្ឋាននេះត្រូវបានកែប្រែ ។ សូមអានតារាងទី ១៣ សម្រាប់សេចក្តីពន្យល់អំពីមាត្រដ្ឋាននេះ ។

*តារាងទី ១៣. មាត្រដ្ឋានភាពប្រកួតប្រជែងផ្នែក CDM*

| | | | |
|---|---|---|---|
| មានភាពប្រកួតប្រជែង | | | |
| AAA | មានភាពប្រកួតប្រជែងខ្លាំងបំផុត | AA | មានភាពប្រកួតប្រជែងខ្លាំង |
| A | មានភាពប្រកួតប្រជែង | BBB | មានភាពប្រកួតប្រជែងខ្លះដែរ |
| ចាត់ទុកថាមានហានុភ័យ | | | |
| BB | ពុំមានភាពប្រកួតប្រជែងគ្រប់គ្រាន់ | B | មានឱកាសទទួលបានជោគជ័យច្រើនជាងបរាជ័យតិចតួច |
| CCC | ពុំមានភាពប្រកួតប្រជែងប៉ុន្មាន | CC | វិនិយោគនៅក្នុងប្រទេសនេះប្រហែលជាមិនសូវទទួលបានជោគជ័យ |
| C | វិនិយោគនៅក្នុងប្រទេសនេះប្រហែលជាមិនទទួលបានជោគជ័យ | D | គ្មានភាពប្រកួតប្រជែង/ពុំសមស្របសម្រាប់ការវិនិយោគ CDM |

ដូចដែលយើងបានឃើញ នៅថ្នាក់ជាតិ ប្រទេសទាំងបីនេះអាចត្រូវចាត់ទុកថា មានហានុភ័យ (វៀតណាម) ឬពុំមានភាពទាក់ទាញ (កម្ពុជា និងឡាវ) សម្រាប់ការវិនិយោគ CDM ។

នៅថ្នាក់គំរោង ដោយហេតុថា អ្នកទិញតែងតែបារម្ភអំពីហានុភ័យ នោះនឹងមានតែបរិមាណគំរោងតិចតួចប៉ុណ្ណោះនៅក្នុងប្រទេសទាំងបីនេះ ដែលអាចទាក់ទាញមូលធនសម្រាប់ការវិនិយោគ ។

## ៥.២ សេចក្តីសន្និដ្ឋាន និងសំណើ

គោលដៅចុងក្រោយនៃ CDM គឺគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព ។ ក៏ប៉ុន្តែ នីតិវិធី CDM មានភាពសាំញ៉ាំពិបាក ហើយទាមទារចំណាយច្រើន ។ ការទាក់ទាញឱ្យបាននូវហិរញ្ញប្បទានគំរោងគឺជាឧបសគ្គចំបងមួយ ។ ដោយយោងទៅលើទំហំនៃទីផ្សារសម្រាប់ឥណទានកាបូនបច្ចុប្បន្ន និងភាពមិនច្បាស់លាស់នៃរបបក្រោយពិធីសារក្យូតូចប់ នោះគំរោង CDM នឹងត្រូវប្រកួតប្រជែងយ៉ាងខ្លាំងជាមួយគ្នា ក៏ដូចជាជាមួយបណ្តាយន្តការអាចបត់បែនបានផ្សេងទៀតរបស់ពិធីសារក្យូតូ ។

នៅប្រទេសវៀតណាម បញ្ហាប្រឈមមុខខ្ពស់បំផុតបច្ចុប្បន្នគឺការធ្វើឱ្យបណ្តាគោលគំនិត CDM អាចយកទៅអនុវត្តបាន តាមបែបសេដ្ឋកិច្ច ។ ប្រហែលជានៅជាសំនួរនៅឡើយដែលថា លំហូរដ៏គំហុកនៃការវិនិយោគ CDM ចូលទៅវៀតណាម ឬបើនិយាយឱ្យច្បាស់ គំរោង CDM ប្រមាណ 10 នឹងត្រូវបានចុះបញ្ជី នៅមុនឆ្នាំ 2012 ។

នៅកម្ពុជា លទ្ធភាពក្នុងការទទួលអនុវត្តគំរោង CDM ចំនួនពីរ-បី នៅក្នុងដំណាក់កាលទី 1 នៃកាតព្វកិច្ចប្រហែលជាមានមិនច្រើនទេ ពិតមែនតែប្រទេសនេះបានធ្វើឱ្យមានការរីកចំរើនច្រើន ក្នុងការកសាងស្ថាប័ន CDM របស់ខ្លួនបើប្រៀបជាមួយនឹងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួចដទៃទៀត ។ ដំណោះស្រាយមួយក្នុងការចាប់យកកាលានុវត្តភាព CDM គឺការទាក់ទាញការចាប់អារម្មណ៍របស់មូលនិធិកាបូនពហុភាគី ដូចជាមូលនិធិកាបូនសម្រាប់អភិវឌ្ឍ

សហគមន៍ (Community Development Carbon Fund: CDCF) និងមូលនិធិជីវៈកាបូន (Bio Carbon Fund: BioCF) ជាដើម ដែលត្រូវបានគេបង្កើតឡើង ដើម្បីជួយឱ្យសហគមន៍ក្រីក្រតូចៗនៅតំបន់ជនបទ ក្នុងការទាញយកប្រយោជន៍ពីហិរញ្ញវត្ថុកាបូន ឬជួយអ្នកវិនិយោគដែលគិតគូរពីកេរ្តិ៍ឈ្មោះរបស់គេ ក្នុងការរកឥណទានដែលគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព ។

សម្រាប់ប្រទេសឡាវ ការឈានជើងចូលទៅក្នុង CDM ប្រហែលជាមានការប្រកួតប្រជែងយ៉ាងខ្លាំង ដោយសារតែភាពពុំអំណោយផលផ្នែក CDM របស់ប្រទេសនេះ និងសកម្មភាពយឺតយ៉ាវរបស់រដ្ឋាភិបាល ក្នុងការបង្កើតរចនាសម្ព័ន្ធ CDM ។ គំរោងវារីអគ្គិសនីប្រហែលជាមានឱកាសប្រសើរជាងគេ ប៉ុន្តែអាចជួបប្រទះនឹងបញ្ហាភាពបន្ថែម ពោលគឺការជជែកវែកញែកអំពីទិដ្ឋភាពនិរន្តរភាពនៃអាងស្តុកទឹក ។ អាស្រ័យហេតុនេះ ប្រទេសឡាវត្រូវតែខិតខំខ្លាំងថែមទៀត ក្នុងការកសាងសមត្ថភាពរបស់ខ្លួន ដើម្បីផ្តល់នូវក្របខ័ណ្ឌជាមូលដ្ឋានគ្រប់គ្រាន់មួយ ដើម្បីឱ្យប្រទេសនេះក្លាយទៅជាគោលដៅ CDM មួយ នៅក្នុងក្រសែភ្នែកអ្នកផ្តល់ជំនួយអន្តរជាតិ ក្នុងចំណោមប្រទេសដែលមានការអភិវឌ្ឍតិចតួច ។

ទោះជាយ៉ាងណាក្តី គេអាចឃើញយ៉ាងច្បាស់នូវតម្លៃផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកវិទ្យា ដែល CDM អាចផ្តល់ជាវិភាគទាន ទៅឱ្យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ។ តែក្នុងរយៈពេលតិចជាងមួយទសវត្សរ៍ប៉ុណ្ណោះ CDM បានចេញពីការពិភាក្សានយោបាយ ហើយក្លាយទៅជាមុខទំនិញថ្មីមួយ ។ ការស្រូបយករបស់ទីផ្សារកាបូននាពេលថ្មីៗនេះបង្ហាញថា ការអភិវឌ្ឍទីផ្សារកាបូនបន្តទៀតនាពេលអនាគតឆាប់ៗនេះ អាចនឹងធ្វើឱ្យមានការភ្ញាក់ផ្អើលសម្រាប់អ្នកឯកទេសកាបូនទាំងនោះ ។ ដោយពិចារណាលើកត្តានេះ និងទស្សនវិស័យរយៈពេលវែងនៃ CDM ក៏ដូចជាបញ្ហាប្រែប្រួលអាកាសធាតុ ប្រទេសទាំងបីត្រូវតែបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការស្វែងរកផលប្រយោជន៍ពី CDM តាមរយៈបណ្តាជំហានជាក់ស្តែង សំដៅកែលំអបរិស្ថានវិនិយោគសម្រាប់ការវិនិយោគ CDM ក៏ដូចជាពីយន្តការផ្សេងទៀតដែលអាចវិវត្តពី CDM បច្ចុប្បន្ន នៅក្នុងរបបគោលនយោបាយអាកាសធាតុអនាគត ។ ការកំណត់រកនូវប្រភេទគំរោងដោយឡែកដែលជាចំណុចខ្លាំងជាក់ស្តែងរបស់ប្រទេស គឺជាប្រការដែលមានសារៈសំខាន់ ។

ការជួយ និងជំរុញអ្នកអភិវឌ្ឍគំរោងក្នុងស្រុក ដើម្បីចូលប្រឡូកក្នុងទីផ្សារកាបូនអន្តរជាតិ ត្រូវតែជាអាទិភាពចំបងមួយ ក្នុងចំណោមអាទិភាពផ្សេងទៀត ដើម្បីជួយពង្រឹងស្ថាប័នជាតិ ។

លើសពីនេះ អាជ្ញាធររបស់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធក្នុងស្រុក ត្រូវតែយល់ច្បាស់ថា ការផ្សព្វផ្សាយរកទីផ្សារ គឺជាភារកិច្ចដ៏សំខាន់មួយ ។ ដោយសារថា គំរោង CDM ផលិតចេញជាមុខទំនិញ CER នៅក្នុងទីផ្សារប្រកបដោយភាពប្រកួតប្រជែង នោះប្រទេសនីមួយៗត្រូវតែប្រកាន់ជំហរប្រតិសកម្ម ជាជាងការរង់ចាំ និងរំពឹងគិតថា ជំនួយឥតសំណងនឹងហូរចូលមកក្នុងប្រទេសខ្លួន ដូចដែលអ្វីបានកើតឡើងនៅក្រោមរបបជំនួយហិរញ្ញវត្ថុខ្លះ មានមូលនិធិបរិស្ថានពិភពលោក (Global Environment Facility: GEF) ជាដើម ។

ជាប្រការសំខាន់ដែលថា សមិទ្ធផលប្រកបដោយផ្លែផ្កា ដែលបានមកពីសកម្មភាពកសាងសមត្ថភាព ត្រូវតែទទួលបាននូវការទ្រទ្រង់ និងបន្តទៀត បន្ទាប់ពីការឧបត្ថម្ភត្រូវបានបញ្ចប់ ។ កិច្ចការនេះអាចធ្វើទៅបាន តាមរយៈកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋាភិបាល ឬអ្នកផ្តល់ជំនួយ ជាពិសេសក្នុងការឆ្លើយតបទៅនឹងតម្រូវការកសាងសមត្ថភាពសម្រាប់ភាគី

ពាក់ព័ន្ធរបស់ជាតិផ្សេងទៀត ដូចជាស្ថាប័នហិរញ្ញវត្ថុ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអ្នកផ្តល់យោបល់ក្នុងស្រុក ឯករាជ្យ ជាដើម ។

# ឯកសារយោង


ALGAS, Asia Least-cost Greenhouse Gas Abatement Strategy – ALGAS, 1998, CD Rom

ASEAN Center for Energy, www.aseanenergy.org/

ASEAN Secretariat - ASEAN FDI Database, 2004, www.aseansec.org/

AT Kearney, 2004. FDI Confidence Index. *Global Business Policy Council, 7*, p. 30

Bank of Lao PDR, http://www.bwtp.org/

CD4CDM, Capacity Development for the CDM, cd4cdm.org/

Ellis J., Corfee-Morlot J., Winkler H., 2004. Taking stock of progress under the clean development mechanism (CDM), OECD, Paris.

Institutional Investor magazine, September 2005

Haites E., 2004. Estimating the market potential for the Clean Development Mechanism: Review of models and lessons learned, PCFplus Report 19, World Bank, Washington

Manso P., 2003. Establishing a National Authority (NA) for the Clean Development Mechanism (CDM): The Costa Rican Experience, OECD, CCNM/GF/SD/ENV(2003)11/FINAL, Paris

Michaelowa A., Jotzo F., 2005. Transaction Costs, Institutional Rigidities and the Size of the Clean Development Mechanism. *Energy Policy* 33 (2005), p. 511-523

Niederberger A., Saner R., 2005, Exploring the relationship between FDI flows and CDM potential, *Transnational Corporation*, 4, 1, p. 1-40

NSS, Vietnam National Strategies Study, 2005, personal communication

Official Energy Statistics from the U.S. Government, www.eia.doe.gov

Pearson B., 2005. The CDM is failing. *Tiempo*, 56, p. 12-16

Point Carbon, 2002. Is there a business case for small-scale CDM projects? Carbon Market Analyst, December 2002

Tan K.G., Wong B., Yin Y., Lee J.Y., Tan A. 2005. Annual IPS-NTU Asean 9+1 Competitiveness Ranking Indices, Marshall Cavendish Academic, Singapore

The World Fact Book, www.cia.gov/cia/publications/factbook/

Sakamoto, T., 2003, Emission Trend in Developing Countries and Measures to Facilitate CDM Implementation in Asia, International Conference on Climate Policy after Marrakech: Toward Global Participation, Hawaii, September 2003 http://ewcraq1.eastwestcenter.org/~marrakech/Sakamoto03.ppt

UNFCCC Secretariat, http://unfccc.int/

U.S. Embassy, Vientiane Laos 2005, Doing business in Lao PDR: A country Commercial Guide for U.S. Business 2005, http://vientiane.usembassy.gov/wwwflaoccg.pdf

World Economic Forum, http://www.weforum.org/